World Vision

# ដើម្បីកុមារ ដើម្បីការផ្លាស់ប្រែ ដើម្បីជីវិត

## របាយការណ៍ប្រចាំឆ្នាំ ២០២៥

ប្រទេសកម្ពុជា



អង្គការទស្សនៈពិភពលោក គឺជាអង្គការគ្រិស្តបរិស័ទជំនួយសង្គ្រោះបន្ទាន់ អភិវឌ្ឍន៍ និងតស៊ូមតិ ប្តេជ្ញាធ្វើការបម្រើកុមារ គ្រួសារ និងសហគមន៍របស់ពួកគេ ដើម្បីឱ្យពួកគេអាចទទួលបានសក្តានុពលពេញលេញ តាមរយៈការដោះស្រាយមូលហេតុដែលជាដើមចមនៃភាពក្រីក្រ និងភាពអយុត្តិធម៌។ អង្គការទស្សនៈពិភពលោក បម្រើប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់សាសនា ពូជសាសន៍ ជនជាតិ ឬភេទឡើយ។

© អង្គការទស្សនៈពិភពលោកអន្តរជាតិ ឆ្នាំ២០២៦
រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះអាចត្រូវបានផលិតឡើងវិញ ក្នុងទម្រង់ណាមួយ ដោយគ្មានការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ លើកលែងតែអត្ថបទដកស្រង់ ខ្លីៗសម្រាប់ការពិនិត្យឡើងវិញ។

បោះពុម្ពផ្សាយដោយអង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា នៅខែមីនា ឆ្នាំ២០២៦។
នាយកការបោះពុម្ពផ្សាយ៖ លោក ដេនេស អ៊ីម៉ានូអែល ហ្គីនទីញ នាយកប្រចាំប្រទេសនៃអង្គការទស្សនៈ ពិភពលោកអន្តរជាតិនៅកម្ពុជា
ការសម្របសម្រួលរបាយការណ៍ ៖ លោកស្រី សរ ពិសី អ្នកឯកទេសជាន់ខ្ពស់ផ្នែកទំនាក់ទំនងសាធារណៈ

យើងស្វាគមន៍មតិយោបល់ និងការសាកសួរទាំងឡាយ និងសូមលើកទឹកចិត្តឱ្យផ្តល់ព័ត៌មានស្តីពីការ ប្រើប្រាស់ខ្លឹមសារដែលមាននៅក្នុងរបាយការណ៍នេះសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល ការស្រាវជ្រាវ ឬកម្មវិធី នានា ក៏ដូចជាការអនុវត្ត ឬការវាយតម្លៃ។



# រៀងរាល់ ៦០* វិនាទី

## មានគ្រួសារមួយទទួល បានទឹកប្រើប្រាស់

## កុមារម្នាក់ដែលស្រេកឃ្លាន ទទួលបានអាហារ

## គ្រួសារមួយទទួលបាន ពីរបៀបដើម្បីជម្នះភាពក្រីក្រ

* ទិន្នន័យអង្គការទស្សនៈពិភពលោកអន្តរជាតិ នៅក្នុងប្រទេសចំនួន ១០០

# បុព្វកថា

## ដោយលោក ផេនេស អ៊ីម៉ានូអ៊ែល ហ្គីនទីញ នាយកប្រចាំប្រទេសនៃអង្គការទស្សនៈពិភពលោក អន្តរជាតិ ប្រចាំនៅកម្ពុជា

### ជម្រាបសួរដៃគូទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្ស ក្នុងការបង្ហាញជូនលោកអ្នកនូវរបាយការណ៍ ស្តីពីផលជះប្រចាំឆ្នាំ ២០២៥ របស់អង្គការទស្សនៈពិភពលោកកម្ពុជា។

ឆ្នាំ ២០២៥ គឺជាឆ្នាំដែលពោរពេញដោយបញ្ហាប្រឈម ជាពិសេសការផ្លាស់ប្តូរដ៏រអាក់រអួល នៅក្នុងវិស័យមនុស្សធម៌ និងការអភិវឌ្ឍ និងផលប៉ះពាល់ផ្នែកមនុស្សធម៌ដែលបណ្តាលមកពីការកើនឡើងនៃជម្លោះតាមព្រំដែន។ ទោះជាយ៉ាងណាក៏ដោយ អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា នៅតែបន្តសម្របខ្លួន ហើយដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយដៃគូទាំងអស់របស់យើង យើងអាចសម្រេចបានលទ្ធផល និងបានគ្របដណ្តប់ដល់ប្រជាពលរដ្ឋចំនួន ៥,៤ លាននាក់ (ជិតមួយភាគបីនៃចំនួនប្រជាពលរដ្ឋសរុបនៅកម្ពុជា) រួមទាំងកុមារចំនួន ៣,១ លាននាក់។

ក្នុងការឆ្លើយតបទៅនឹងវិបត្តិមនុស្សធម៌ដែលបណ្តាលមកពីជម្លោះព្រំដែន ការឆ្លើយតបកិច្ចការមនុស្សធម៌ របស់អង្គការទស្សនៈពិភពលោក បានជួយដល់ជនភៀសសឹកជាង ១៤៤.០០០ នាក់ រួមទាំងកុមារជាង ៤៣.០០០ នាក់ និងជនមានពិការភាពចំនួន ១.១០០ នាក់ នៅទីតាំងភៀសសឹកចំនួនជាង ១០០ កន្លែង។ តាមរយៈការធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដៃគូមនុស្សធម៌ អង្គការទស្សនៈ ពិភពលោកបានផ្តល់ជំនួយសង្គ្រោះជីវិត ដូចជា ទឹកស្អាត បង្គន់អនាម័យចល័ត កញ្ចប់អនាម័យស្ត្រី ស្បៀងអាហារ និងសម្ភារៈមិនមែនស្បៀង ការអប់រំបណ្តោះអាសន្ន សុខភាព និងអាហារូបត្ថម្ភ សន្តិសុខស្បៀង និងជំនួយ សាច់ប្រាក់ កិច្ចការពារ និងសេវាគាំទ្រផ្នែកចិត្តសង្គម។ លើសពីនេះ អង្គការទស្សនៈពិភពលោក បានបង្កើតទីធ្លាកុមារមេត្រី ចែកសម្ភារៈសិក្សា និងផ្តល់ការគាំទ្រផ្នែកចិត្តសង្គមដល់ប្រជាពលរដ្ឋជាង ៣.២០០ នាក់។ ដើម្បីគាំទ្រដល់សហគមន៍ងាយរងគ្រោះបំផុតមួយចំនួនដែលរងផលប៉ះពាល់ដោយជម្លោះនេះ អង្គការទស្សនៈពិភពលោកបានជួយឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូនចំនួន ២.២០០ នាក់ ដោយផ្តល់កញ្ចប់អាហារូបត្ថម្ភ និងកន្លែងមានសុវត្ថិភាព ព្រមទាំងពង្រីកសម្ភាររូបវន្តទឹកស្អាត និងអនាម័យ (WASH) និង ជម្រកសង្គ្រោះបន្ទាន់។

ទោះបីជាស្ថិតក្នុងបរិបទប្រឈមដែលកំពុងសាកល្បងលើភាពធន់របស់កម្ពុជាក៏ដោយ ក៏នេះជាការលើកទឹកចិត្តមួយផងដែរ ដែលបានមើលឃើញសាមគ្គីភាពរបស់មហាជន និងដៃគូនៅកម្ពុជា តាមរយៈការបរិច្ចាគ ជំនួយសប្បុរសធម៌នៅក្នុងប្រទេស តាមរយៈអង្គការទស្សនៈពិភពលោក និងដៃគូមនុស្សធម៌ផ្សេងទៀតទាំងអស់។



មនុស្សរាប់រយនាក់ រួមទាំងបុគ្គលិកអង្គការទស្សនៈពិភពលោក ដៃគូអភិវឌ្ឍន៍ និងសាជីវកម្ម ដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ចំនួន ១៥ បានផ្តល់វិភាគទានជាហិរញ្ញវត្ថុ និងជាសម្ភារៈ តាមរយៈការឆ្លើយតប កិច្ចការមនុស្សធម៌ និងការគាំទ្រដល់ការស្តារឡើងវិញទាន់ពេលវេលាដោយអង្គការទស្សនៈពិភពលោក។

ការិយាល័យគាំទ្រមួយចំនួនរបស់អង្គការទស្សនៈពិភពលោកនៅជុំវិញសកលលោក ក៏បានចូលរួមក្នុងកម្លាំងសាមគ្គីនេះផងដែរ ដោយផ្តល់ធនធានបន្ថែម ឬរៀបចំកម្មវិធីដែលមានស្រាប់មួយចំនួនឡើងវិញ ដើម្បីគាំទ្រដល់កម្មវិធីមនុស្សធម៌ និងការស្តារឡើងវិញទាន់ពេលវេលាដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា។

លើសពីការឆ្លើយតបកិច្ចការមនុស្សធម៌ និងការស្តារឡើងវិញទាន់ពេលវេលា មានរឿងរ៉ាវនៃភាពជាដៃគូរួមគ្នា ការផ្លាស់ប្តូរប្រកបដោយការផ្លាស់ប្រែ ការរួមចំណែកដល់ការផ្លាស់ប្តូរប្រព័ន្ធ និងគោលនយោបាយ និងវឌ្ឍនភាពពិតប្រាកដក្នុងផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GED-SI) នៅទូទាំងកម្មវិធីទាំងអស់ ដូចដែលអ្នកអាចនឹងបានអាននៅក្នុងរបាយការណ៍នេះ។ ក្នុងចំណោមសមិទ្ធផលផ្សេងទៀត កម្មវិធីទឹកស្អាត និងអនាម័យ (WASH) របស់អង្គការទស្សនៈពិភពលោក បានរួមចំណែកដល់ការប្រកាសបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលនៅក្នុងសហគមន៍ចំនួន ៤៥១។ កុមារី និងកុមារាជាង ២២.០០០ នាក់ បានចូលរួមក្នុង កម្មវិធីកិច្ចការពារកុមារនិងការចូលរួម ដែលរួមចំណែកដល់ការបែងចែកធនធានសម្រាប់កម្មវិធីការពារកុមារនៅក្នុង ១០៩ ឃុំ/សង្កាត់។ កុមារបាត់បង់ឱកាសចំនួន ១៩.៤០០ នាក់ មានលទ្ធភាពទទួលបានការអប់រំកាន់តែប្រសើរឡើង ហើយសិស្សជាង ១៦៤.០០០ នាក់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីអប់រំ គ្រប់ប្រភេទ។ កុមារចំនួន ១.១៥០ នាក់ ត្រូវបានពិនិត្យរកបញ្ហាកង្វះ អាហារូបត្ថម្ភ ហើយត្រូវបានម្តាយ/អ្នកថែទាំបញ្ជូន ទៅមូលដ្ឋានសុខាភិបាល សមស្របដែលនៅជិតបំផុត។ ប្រជាពលរដ្ឋប្រមាណ ២.៤៨៨ គ្រួសារ បានបង្កើនអក្ខរកម្មហិរញ្ញវត្ថុរបស់ពួកគេ ហើយ ស្ត្រីចំនួន ២.៣៧៥ នាក់ បានចូលរួមក្នុងសកម្មភាព បង្កើតប្រាក់ចំណូល។ សហគមន៍ចំនួន ៣៧ បានអនុវត្តសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយផលប៉ះពាល់។ ឃុំ/សង្កាត់ចំនួន ៩៧៦ បានបែងចែកថវិកាមូលដ្ឋានចំនួន ៨០៨.៦៤៥ ដុល្លារអាមេរិកសម្រាប់គាំទ្រដល់ការអនុវត្ត គណនេយ្យភាពសង្គម ដើម្បីបង្កើនលទ្ធភាពទទួលបាន និងគុណភាពនៃការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋាន។ ការចាប់ផ្តើមយុទ្ធនាការគ្រប់គ្រាន់ ENOUGH ស្តីពីអាហារូបត្ថម្ភ នៅថ្នាក់ក្រោមជាតិ និងមានការចូលរួមដោយ ជនមានពិការភាពចំនួន ១០.៧៥២ នាក់ (រួមទាំងកុមារ ៥.២០៩ នាក់)។

លើសពីនេះ ឆ្នាំ ២០២៥ ក៏ជាឆ្នាំទី ៥៥ នៃការប្តេជ្ញាចិត្តរយៈពេលវែងរបស់អង្គការទស្សនៈពិភពលោក ក្នុងការបម្រើកុមារ និងសហគមន៍ដែលងាយ



រងគ្រោះបំផុតនៅកម្ពុជាផងដែរ។ យើងមានសេចក្តីសោមនស្ស និង មានមោទនភាពដែលបានក្លាយជាផ្នែកមួយនៃរឿងរ៉ាវស្តីពីភាពធន់ និងក្តីសង្ឃឹមរបស់ប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថាប័នម្ចាស់ជំនួយ ដៃគូរដ្ឋាភិបាល អ្នកគាំទ្រជាសាជីវកម្ម សហគមន៍ អាជ្ញាធរមូលដ្ឋាន យុវជន កុមារ និងជាចុងក្រោយ បុគ្គលិកដ៏ប្រឹងប្រែងរបស់អង្គការទស្សនៈពិភពលោក ដែលការប្តេជ្ញាចិត្តរបស់ពួកគេបានធ្វើឱ្យយើងសម្រេចបានសមិទ្ធផលទាំងនេះ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះការគាំទ្រដ៏សប្បុរស និងការប្តេជ្ញាចិត្តរបស់អស់លោកអ្នកក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើតផលជះជាវិជ្ជមានលើជីវិតរបស់កុមារគ្រប់រូបនៅកម្ពុជា។

យើងទន្ទឹងរង់ចាំបន្តភាពជាដៃគូរបស់យើងនៅក្នុងឆ្នាំ២០២៦នេះ។ ផ្លូវដើរទៅមុខនៅតែមានឧបសគ្គ ប៉ុន្តែខ្ញុំមានទំនុកចិត្តថា តាមរយៈកិច្ចខិតខំប្រឹងប្រែង ភាពច្នៃប្រឌិត ភាពជាដៃគូ ភាពធន់ និងភាពស្មោះត្រង់ចំពោះ គោលដៅរួមរបស់យើង យើងទាំងអស់គ្នាពិតជាអាចសម្រេចបានទស្សនវិស័យរបស់យើង ដែលចង់ឃើញ “កុមារគ្រប់រូបនៅកម្ពុជា មានជីវិតពេញបរិបូរណ៍” ។

សូមអរគុណច្រើន!

# មាតិកា


## .០១

ការឆ្លើយតបបន្ទាន់ផ្នែកមនុស្សធម៌ និង
ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

## .០២

គាំទ្រកុមារដែលងាយរងគ្រោះបំផុត

## .០៣

**ដើម្បីកុមារ៖**
សមិទ្ធផលសំខាន់ៗនៃ
សុខុមាលភាពកុមារ

## .០៤

**ដើម្បីការផ្លាស់ប្រែ៖**
សមិទ្ធផលសំខាន់ៗនៃការពង្រឹង
ប្រព័ន្ធក្នុងមូលដ្ឋាន

## .០៥

**ដើម្បីជីវិត៖**
ការប្តេជ្ញាចិត្តរបស់យើងក្នុងការបង្កើត
ឱ្យមានការផ្លាស់ប្រែដ៏យូរអង្វែង

# ការអបអរសាទរខួប ៥៥ ឆ្នាំ នៃផលជះ និងការផ្លាស់ប្រែ

ជាងប្រាំទសវត្សរ៍កន្លងមកនេះ អង្គការទស្សនៈពិភពលោកបានឈរប្រកៀកស្មាជាមួយប្រជាពលរដ្ឋកម្ពុជា ហែលឆ្លងពេលវេលាដែលពោរពេញដោយការលំបាក និងភាពជោគជ័យ ដោយឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់ កសាងក្តីសង្ឃឹមឡើងវិញ និងបង្កើនភាពអង់អាចដល់គ្រួសារ និងសហគមន៍ ដើម្បីកសាងអនាគតដ៏ល្អប្រសើរសម្រាប់កុមារ។ ចាប់ពីថ្ងៃដំបូងនៃការសង្គ្រោះមនុស្សធម៌ រហូតដល់ការអភិវឌ្ឍសហគមន៍ចម្រុះ នាពេលបច្ចុប្បន្ន អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា គឺជាសាក្សីផង និងជាដៃគូផងចំពោះការផ្លាស់ប្រែដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជា។ រួមគ្នាជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយ ថ្នាក់ដឹកនាំជំនឿ សហគមន៍ និងកុមារ យើងបានស្តារជីវិតឡើងវិញ ធ្វើឱ្យអនាគតកាន់តែភ្លឺស្វាង និងផ្តល់ក្តីសង្ឃឹមជាថ្មី។

តាមរយៈកម្មវិធីប្រកបដោយនវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការក្នុងមូលដ្ឋានដ៏រឹងមាំ យើងបានជួយដល់ ជីវិតមនុស្សរាប់លាននាក់ ដោយធានាថា កុមាររីកចម្រើននៅក្នុងបរិយាកាសដែលមានសុវត្ថិភាព និងការយកចិត្តទុកដាក់។ វិធីសាស្ត្ររួមរបស់យើង (ការកែលម្អការអប់រំ និងការថែទាំសុខភាព ការពង្រឹងកិច្ចការពារកុមារ និងការបង្កើតឱកាសប្រកបរបរចិញ្ចឹមជីវិត) ដោះស្រាយឫសគល់នៃភាពក្រីក្រ និង វិសមភាព។ ផ្អែកតាមទស្សនវិស័យ “កុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍” យើងដាក់កុមារជាចំណុចស្នូលនៃអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ។

ផលជះរបស់អង្គការទស្សនៈពិភពលោក ស្តែងឡើងយ៉ាងច្បាស់ ក្នុងចំណុចសំខាន់ៗដែលបានសម្រេច រួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការគាំទ្រយុទ្ធសាស្ត្រជាតិដែលបន្សុីគ្នានឹងគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាពជាពិសេសក្នុងវិស័យអាហារូបត្ថម្ភ ការអប់រំ និងទឹកស្អាត និងអនាម័យ (WASH) ។ គំនិតផ្តួចផ្តើម ដូចជា ផែនការសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាលើកុមារ និងយុទ្ធនាការ “កុមារគ្រប់រូបរីកចម្រើន” គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរួមរបស់យើងចំពោះសិទ្ធិនិងសុខុមាលភាពរបស់កុមារ។

## របៀបដែលយើងបានចាប់ផ្តើម

### ១៩៧០

អង្គការទស្សនៈពិភពលោកអន្តរជាតិ ចាប់ផ្តើមប្រតិបត្តិការជាមួយប្រទេសកម្ពុជា តាមរយៈជំនួយសង្គ្រោះបន្ទាន់។

### ១៩៧៥

មន្ទីរពេទ្យកុមារជាតិដំបូង ត្រូវបានសាងសង់ឡើងដោយមានការរួមចំណែកពីការិយាល័យគាំទ្ររបស់អង្គការទស្សនៈពិភពលោកនៅជុំវិញពិភពលោក។

### ១៩៨០

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម អង្គការទស្សនៈពិភពលោកគឺជាអង្គការអន្តរជាតិដំបូងគេដែលវិលត្រឡប់មកកម្ពុជាវិញ។

### ១៩៩៥

ការចាប់ផ្តើមកម្មវិធីទំនុកបម្រុងកុមាររបស់អង្គការទស្សនៈពិភពលោក ដោយនាំមកនូវវិធីសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍសហគមន៍។

### ២០០៦

ដោយសារការវិវត្តតម្រូវការរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត និងការវិវត្តរបស់អង្គការទស្សនៈពិភពលោកផ្ទាល់ យើងបានដាក់ចេញវិធីសាស្ត្ររួមមួយសម្រាប់កម្មវិធីអភិវឌ្ឍន៍របស់យើង។

# រយៈពេល ៥៥ ឆ្នាំនៃក្តីសង្ឃឹម ការផ្លាស់ប្រែ និងអនាគតដែលយើងកសាងរួមគ្នា

នៅឆ្នាំ ២០២៥ យើងបានពង្រឹងការប្តេជ្ញាចិត្តរបស់យើងចំពោះបរិយាបន្ន យេនឌ័រ និងពិការភាព ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការការពារបរិស្ថាន ការចូលរួមរបស់កុមារ និងគណនេយ្យភាពសង្គម តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoUs) ជាមួយក្រសួង និងក្រុមប្រឹក្សាសំខាន់ៗ ។ ម្ចាស់ជំនួយ ដូចជា ធនាគារពិភពលោក ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍ស្វីស (SDC) សហភាពអឺរ៉ុប និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) បន្តដើរតួនាទីសំខាន់ក្នុងការពង្រីកដំណោះស្រាយបែបច្នៃប្រឌិត ចាប់ពីការអភិវឌ្ឍកុមារតូច រហូតដល់ការជំរុញ របរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុ ខណៈដែលដៃគូសាជីវកម្មបានពង្រីកកិច្ចខិតខំប្រឹងប្រែងទាំងនេះតាមរយៈការបង្កើតផលជះបន្ត និងបាចសាចនៅក្នុងសហគមន៍ជួបការលំបាក និងការបំផុសវប្បធម៌នៃតម្លៃរួម និងកំណើនប្រកបដោយបរិយាបន្ន ។

ស្របពេលដែលយើងអបអរសាទរខួប ៥៥ ឆ្នាំនៃវត្តមាននៅកម្ពុជា ដំណើរប្រកបដោយទំនុកចិត្ត និងភាពជឿជាក់នេះ បានត្រួសត្រាយផ្លូវសម្រាប់ជំពូកថ្មីមួយ គឺការចាប់ផ្តើមការរៃអង្គាសថវិកាក្នុងស្រុក ដើម្បីកៀរគរ ធនធាន និងពង្រីកវិសាលភាពរបស់យើង ជាពិសេសក្នុងការឆ្លើយតបទៅនឹងតម្រូវការមនុស្សធម៌នាពេលថ្មីៗនេះ។ តាមរយៈគំនិតផ្តួចផ្តើមនេះ យើងបានជួយគាំទ្រដល់ជំរំចំនួន ៩២ ក្នុងចំណោមជំរំសរុប ១៩២ (ស្មើនឹងជិត ពាក់កណ្តាលនៃចំនួនទីតាំងភៀសសឹកសរុប) ដោយផ្តល់ជំនួយបន្ទាន់ដល់អ្នកដែលរងផលប៉ះពាល់ខ្លាំងជាងគេ។ បង្គោលចរនេះឆ្លុះបញ្ចាំងពីភាពរហ័សរហួន និងការឆ្លើយតបរបស់យើង ក្នុងការផ្តល់ដំណោះស្រាយ ទាន់ពេលវេលា នៅពេលមានបញ្ហាប្រឈមកើតឡើង។

## កន្លែងដែលយើងស្ថិតនៅបច្ចុប្បន្ន

### ២០១៧

កម្មវិធីអង្គការទស្សនៈពិភពលោក សង្កត់ធ្ងន់លើការកៀរគរសហគមន៍ វិធីសាស្រ្តបច្ចេកទេសជាយុទ្ធសាស្រ្ត និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន តាមរយៈយុទ្ធនាការ “It Takes a World”។

### ២០២១

ការឆ្លើយតបរបស់អង្គការទស្សនៈពិភពលោកទៅនឹងវិបត្តិកូវីដ-១៩ បានគ្របដណ្តប់ដល់ប្រជាពលរដ្ឋជាង ១ លាននាក់នៅកម្ពុជា តាមរយៈការផ្តល់សារស្តីពីឥរិយាបថ និង សកម្មភាពការពារ។

### ២០២៣

រដ្ឋយុទ្ធសាស្រ្តថ្មីត្រូវបានដាក់ចេញ ដើម្បីបម្រើតម្រូវការថ្មីៗរបស់កុមារី និងកុមារាដែលងាយរងគ្រោះបំផុត ចំនួន ៥ លាននាក់នៅកម្ពុជា។

### ២០២៥

យុទ្ធសាស្រ្តប្រចាំប្រទេសត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ដើម្បីបញ្ចូលមេរៀន ដែលទទួលបាន និងសម្របខ្លួនទៅនឹងការប្រែប្រួលបរិបទនៅកម្ពុជា។ យើងនៅតែប្តេជ្ញារក្សាការសន្យារបស់យើងចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុតដោយមិនទុកនរណាម្នាក់ចោល និងរួមចំណែកដល់ចក្ខុវិស័យឆ្នាំ ២០៣០ របស់កម្ពុជា ។ អង្គការទស្សនៈពិភពលោក ក៏បាន និងកំពុងឆ្លើយតបយ៉ាងសកម្មចំពោះតម្រូវការបន្ទាន់របស់ជនភៀសសឹកដែលរងផលប៉ះពាល់ដោយជម្លោះព្រំដែនផងដែរ។





# ចំណុចលេចធ្លោនៃការឆ្លើយតបកិច្ចការមនុស្សធម៌

## ការគាំទ្រដល់កុមារ និងគ្រួសារដែលផ្លាស់ទីលំនៅដោយសារជម្លោះព្រំដែនកម្ពុជា-ថៃ

អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា បានផ្ដល់ជំនួយសង្គ្រោះជីវិតដល់ជនភៀសសឹកចំនួន ១៤០.០០០ នាក់នៅទូទាំងខេត្តបន្ទាយមានជ័យ ព្រះវិហារ សៀមរាប ឧត្ដរមានជ័យ និងបាត់ដំបង។ តាមរយៈការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ ដៃគូមនុស្សធម៌ និងអ្នកគាំទ្រក្នុងវិស័យឯកជន ការឆ្លើយតបនេះបានដោះស្រាយតម្រូវការបន្ទាន់ក្នុងផ្នែកអប់រំ កិច្ចការពារ សន្តិសុខស្បៀង សុខភាព និងអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ (WASH) និងជម្រក។

**១៤០.០០០នាក់**

**ចំនួនដែលបានគ្របដណ្ដប់ដល់ជនភៀសសឹកក្នុងស្រុក**

មនុស្សពេញវ័យ ៩៧.៧១២ នាក់ ស្ត្រី ៥៤.១៨៦ នាក់
កុមារ ៤៣.១៤៨ នាក់
ជនមានពិការភាព ១.១៣៣ នាក់
ប្រជាពលរដ្ឋ ៣៨.៨០០ គ្រួសារ

### កិច្ចការពារកុមារ និងការថែរក្សាសុខុមាលភាព

- ទីធ្លាកុមារមេត្រីចំនួន ៤៥ ទីតាំងត្រូវបានបង្កើតឡើង ដោយផ្ដល់នូវបរិយាកាសសុវត្ថិភាពសម្រាប់ការសិក្សារៀនសូត្រ និងការថែទាំផ្នែកចិត្តសង្គម។
- ប្រជាពលរដ្ឋចំនួន ១៤.៤៧២ នាក់ បានទទួលការគាំទ្រផ្នែកចិត្តសង្គម។
- យន្តការផ្ដល់មតិកែលម្អ និងយន្តការដាក់បណ្ដឹងចំនួន ៣៤ ត្រូវបានបង្កើតឡើងដើម្បីធានាគណនេយ្យភាព និងការចូលរួមរបស់សហគមន៍។

### ការស្ដារការសិក្សារៀនសូត្រឡើងវិញសម្រាប់កុមារភៀសសឹក

- ទីធ្លាសិក្សាបណ្ដោះអាសន្នចំនួន ៥៤ ទីតាំងត្រូវបានបង្កើតឡើងនៅទីតាំងភៀសសឹក។

**សម្ភារៈប្រើប្រាស់៖**

- កាបូបស្ពាយចំនួន ៩.៣៨០
- សៀវភៅសរសេរ និងសៀវភៅរឿងចំនួន ២២.៥២៥ ក្បាល
- សម្ភារៈសិក្សាចំនួន ៤.០៣៥ កញ្ចប់
- ប៊ិច ខ្មៅដៃ បន្ទាត់ ប្រដាប់ខួងខ្មៅដៃ ជ័រលុប ហ្វឺតសរសេរ ក្ដារខៀន និងប្រដាប់ខួងខ្មៅដៃ ចំនួន ៣០.៨០៨។

### ការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភសង្គ្រោះជីវិត

- អង្ករ ៨.១៧៥ គីឡូក្រាម ត្រូវបានចែកជូន
- ត្រីខ ២.១៩៦ កំប៉ុង ត្រីងៀត ១៦០ គីឡូក្រាម និងប្រេងឆា ១០០ លីត្រ
- នំនួទី ៩.៩០០ កញ្ចប់ និងអាហារបំប៉ន RUSF/RUTF ៣.៥០៧ កញ្ចប់ ត្រូវបានចែកជូនដើម្បីបង្ការកង្វះអាហារូបត្ថម្ភ
- ទឹកដោះគោ ១.២០០ លីត្រ ត្រូវបានចែកជូនដល់កុមារតូចៗ។

# ចំណុចលេចធ្លោនៃការឆ្លើយតបកិច្ចកាមនុស្សធម៌

## សេវាសុខភាពចាំបាច់ និងកិច្ចគាំពារមាតា

- ស្ត្រីមានផ្ទៃពោះ ២.២២៦ នាក់ ទទួលបានការគាំទ្រផ្នែកសុខភាពមាតា និងអាហារូបត្ថម្ភ។
- ការបន្តទទួលបានសេវាសុខភាព តាមរយៈការពង្រឹងមណ្ឌលសុខភាពក្នុងមូលដ្ឋាន រួមទាំងការសម្រាលកូនដោយសុវត្ថិភាព និងការថែទាំចាំបាច់សម្រាប់ទារកទើបកើត។

## ទឹកស្អាត និងអនាម័យ (WASH)

- កន្លែងលាងដៃចំនួន ៨ និងធុងស្តុកទឹកចំនួន ២០ ត្រូវបានតម្លើង
- បង្គន់អនាម័យចំនួន ៩៧ បង្គន់សង់ថ្មីចំនួន ៧០ និងសម្ភារៈសាងសង់បង្គន់ចំនួន ៤៩ ត្រូវបានផ្តល់ជូន
- ការចែកសម្ភារៈអនាម័យផ្ទាល់ខ្លួនចាំបាច់៖ សាប៊ូបោកខោអាវ ២៦០ គីឡូក្រាម សាប៊ូដុសខ្លួន ៩៦៦ ដុំ ច្រាស/ថ្នាំដុសធ្មេញ ៨០០ និងសាប៊ូកក់សក់ ៦២៦ ដប
- ប្រព័ន្ធថាមពលព្រះអាទិត្យសម្រាប់ម៉ាស៊ីនបូមទឹកចំនួន ១៤ ឈុត។

## ជម្រក និងសម្ភារៈមិនមែនស្បៀងសម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរទឹកស្អាត និងអនាម័យ (WASH)

- តង់ ៤៣ កន្ទេល ១.៨៨៣ និងកៅអីបត់ ២១៥ ត្រូវបានចែកជូន។
- សម្លៀកបំពាក់សម្រាប់កុមារ និងមនុស្សពេញវ័យចំនួន ១.៩៩២ កំប្លេ។
- ភួយ និងកន្សែងពោះគោចំនួន ២.២៣៥ ត្រូវបានផ្តត់ផ្គង់ដល់គ្រួសារ។
- សម្ភារៈគាំទ្រក្នុងគ្រួសារ រួមមានធុងប្លាស្ទិក ស្រោមដៃ កន្ត្រៃ និងមុង ចំនួន ១.៩៦៣ កញ្ចប់។

## ការសម្របសម្រួល និងភាពជាដៃគូ

អង្គការទស្សនៈពិភពលោក បានសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ (NCDM) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) អាជ្ញាធរខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដៃគូអ្នកដឹកនាំជំនឿ និងវិស័យឯកជន។ អង្គការទស្សនៈពិភពលោកបានធ្វើជាសហប្រធានក្រុមការងារឧបត្ថម្ភសាច់ប្រាក់ និងក្រុមការងារទឹកស្អាត និងអនាម័យ (WASH) ជាមួយអង្គការយូនីសេហ្វ (UNICEF) ក្រោមក្រុមការងារបច្ចេកទេសនៃវេទិកាឆ្លើយតប មនុស្សធម៌ (HRF) ដើម្បីពង្រឹងការសម្របសម្រួលពហុវិស័យ និងបង្កើនប្រសិទ្ធភាពនៃជំនួយមនុស្សធម៌។



#រឿងរ៉ាវ



# ការស្វែងរកមិត្តភក្តិ ការនឹកផ្ទះ៖ រឿងរ៉ាវរបស់ លីតា

## ការរៀនសូត្រ ការគិតស្រមៃ និងការសម្របខ្លួន៖ រឿងរ៉ាវរបស់ លីតា ឆ្លុះបញ្ចាំងពីភាពរឹងមាំរបស់កុមារភៀសសឹក

លីតា ដែលទើបតែមានអាយុ ៧ ឆ្នាំ បានដឹងរួចទៅហើយពីរបៀបធ្វើឱ្យមនុស្សយល់ថាពួកគេទទួលបានការស្វាគមន៍។ តាមរយៈស្នាមញញឹមដ៏ស្រស់ស្រាយ និងសំឡេងប្រកបដោយភាពជឿជាក់ សិស្សថ្នាក់ទី ១ រូបនេះ បានស្វាគមន៍ភ្ញៀវនៅទីតាំងភៀសសឹកក្នុងខេត្តព្រះវិហារ ដោយពោលពាក្យរាក់ទាក់ដែលនាង បានរៀនពីបណ្តាញសង្គម៖ “Ni hao, ni hao ma”។ នាងបាននិយាយស្វាគមន៍ជាភាសាបរទេស អមដោយការសំពះតាមប្រពៃណីខ្មែរ ដោយលើកដៃប្រណំប្រកបដោយក្តីគោរព ពោលគឺនាងមិនដែលភ្លេចវប្បធម៌របស់នាងឡើយ សូម្បីតែនៅក្នុងមជ្ឈដ្ឋានដែលនាងមិនធ្លាប់ស្គាល់។

លីតា មានចរិតរួសរាយរាក់ទាក់ និងចង់ចេះចង់ដឹង។ នាងចូលចិត្តជួបមនុស្សថ្មីៗ ហើយជារឿយៗ តែងតែស្វាគមន៍ភ្ញៀវរួមជាមួយនឹងកុមារដែលមានអាយុស្របាលនាង ដោយបង្ហាញយ៉ាងមានមោទនភាព នូវអ្វីដែលនាងបានរៀន។ ភាពបើកចំហរបស់នាងធ្វើឱ្យនាងមានភាពលេចធ្លោនៅក្នុងទីតាំងភៀសសឹកដ៏មមាញឹក ដែលប្រជាពលរដ្ឋជាច្រើនគ្រួសារបានមករស់នៅផ្តុំគ្នា ក្រោយការចាកចេញពីភូមិរបស់ពួកគេ ដើម្បីស្វែងរកទីសុវត្ថិភាព។

# នៅពេលសួរអំពីក្តីស្រមៃរបស់នាង លីតា បាននិយាយដោយមិនស្ទាក់ស្ទើរថា “ខ្ញុំចង់ដាំបន្លែ។ ខ្ញុំចង់ធ្វើជាគិលានុបដ្ឋាយិកា”។

នាងចូលចិត្តបន្លែ និងសង្ឃឹមថា ថ្ងៃណាមួយ នាងនឹងក្លាយជាអ្នកថែសួន។ ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ក៏ជំរុញទឹកចិត្តឱ្យនាងស្រមៃចង់ក្លាយជាគិលានុបដ្ឋាយិកាផងដែរ។ នេះជាមហិច្ឆតាមួយដែលឆ្លុះបញ្ចាំង ទាំងសេចក្តីសប្បុរស និងភាពធន់របស់នាង។

លីតា គឺជាកូនច្បងក្នុងចំណោមបងប្អូនស្រីពីរនាក់។ ប្អូនៗរបស់នាងមានអាយុត្រឹមតែ ៣ ឆ្នាំ និង ២ ខែប៉ុណ្ណោះ។ នាងត្រូវចាកចេញពីភូមិកំណើតជាមួយគ្រួសាររបស់នាង និងផ្លាស់ទីទៅទីតាំងភៀសសឹក ដើម្បីសុវត្ថិភាព។ ក្នុងអំឡុងពេលនៃការជម្លៀសចេញភ្លាមៗ លីតា បានរត់ទៅមុនជាមួយអ្នកជិតខាងរបស់នាង ខណៈដែលម្តាយរបស់នាងស្ថិតនៅជួរក្រោយ គឺគាត់ជិះម៉ូតូដឹកប្អូនស្រីពៅរបស់ លីតា ដែលមានអាយុទើបតែ ២ ខែ រួមជាមួយនឹងសាច់ញាតិផ្សេងទៀត។

ទោះបីជាមានភាពចលាចលយ៉ាងណាក៏ដោយ ក៏ លីតា បានសម្របខ្លួនយ៉ាងឆាប់រហ័ស។ ក្នុងការរស់នៅជាមួយសាច់ញាតិ និងកុមារដែលមានអាយុស្រាបាលនាង លីតា បានរាប់អានមិត្តថ្មី និងស្វែងរកភាពកក់ក្តៅ ពីមនុស្សដែលនាងធ្លាប់ស្គាល់មុខ។ ចរិតចូលចិត្តលេងសើច និងស្វាហាប់របស់នាង បានស្តែងឡើងយ៉ាងច្បាស់ និងហាក់ផ្តល់ឱ្យនាងនូវអារម្មណ៍ធូរស្បើយពីទុក្ខសោកនៃការរស់នៅឆ្ងាយពីផ្ទះបានមួយគ្រាៗ។ ផ្ទុយទៅវិញនៅពេលសួរថាតើនាងប្រាថ្នាចង់បានអ្វីជាងគេ ចម្លើយរបស់នាងគឺសាមញ្ញ និងច្បាស់លាស់។ លីតា និយាយថា “ខ្ញុំចង់ត្រឡប់ទៅផ្ទះវិញ”។

នៅទីតាំងភៀសសឹកនោះ លីតា បានចូលរៀនថ្នាក់បណ្តោះអាសន្ន និងទៅលេងជាប្រចាំនៅទីធ្លាកុមារមេត្រី (កន្លែងមានសុវត្ថិភាពដែលបង្កើតឡើងសម្រាប់ការរៀនសូត្រ ការលេង និងសកម្មភាពច្នៃប្រឌិត)។ នៅទីនេះ កុមារគូរគំនូរ លេងល្បែងកំសាន្ត និងចូលរួមក្នុងសកម្មភាពដែលជួយស្តារអារម្មណ៍ប្រក្រតីភាពឡើងវិញដល់ជីវិតប្រចាំថ្ងៃរបស់ពួកគេ។

លីតា ក៏ទទួលបានឯកសណ្ឋានសិស្ស ទឹកដោះគោ ទំចំណី និងសម្ភារៈសិក្សាផងដែរ។ នៅពេលហុចក្រដាសមួយសន្លឹក និងខ្មៅដៃឱ្យនាង លីតា ចាប់ផ្តើមគូរយ៉ាងអន្ទះសា ដោយគូសវាសរូបភាព និងហាត់សរសេរតួអក្សរ ដែលកុមារនៅថ្នាក់មត្តេយ្យ និងថ្នាក់ទី ១ កំពុងរៀនសរសេរ។









#រឿងរ៉ាវ



# ពីភាពស្ងៀមស្ងាត់ទៅជាភាពជាអ្នកដឹកនាំ៖ តើការស្ម័គ្រចិត្តបានផ្លាស់ប្រែជីវិតរបស់ រដ្ឋា និង សហគមន៍របស់នាងយ៉ាងដូចម្តេច?

## ការជម្នះឧបសគ្គ៖ តើភាពក្លាហាន និងឱកាសបានប្រែក្លាយក្តីស្រមៃទៅជាការពិតយ៉ាងដូចម្តេច?

កាលពីប៉ុន្មានឆ្នាំមុន រដ្ឋា ហាក់ដូចជារស់នៅក្នុងពិភពលោកដែលតូចចង្អៀត និងគ្មានក្តីសង្ឃឹម។ បន្ទាប់ពីរៀនចប់ថ្នាក់ទី ១២ នាងនៅតែផ្ទះ គ្មានការងារធ្វើ និងគ្មានទិសដៅច្បាស់លាស់។ ជំងឺរបស់ឪពុកនាង បានបង្កើនការលំបាករបស់គ្រួសារកាន់តែខ្លាំង ហើយភាពភ័យខ្លាចបានរារាំងមិនឱ្យនាងស្វែងរកឱកាស។ នាងបានរៀបរាប់ថា “ខ្ញុំបានក្លាយជាមនុស្សស្ងៀមស្ងាត់ ដែលមិនសូវនិយាយស្តី គេចវេសពីមនុស្សម្នា សូម្បីតែអាផ្ទាធរ និងស្អប់ខ្លួនឯងដែលមិនអាចជួយ [គ្រួសារ] របស់ខ្ញុំបាន។”

អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្រែនៅឆ្នាំ ២០២០ នៅពេលដែល រដ្ឋា បានចូលរួមជាមួយអង្គការទស្សនៈពិភពលោកក្នុងនាមជាយុវជនស្ម័គ្រចិត្ត។ ដំបូងឡើយ នាងមានមន្ទិលសង្ស័យចំពោះខ្លួនឯង ប៉ុន្តែដោយមានការលើកទឹកចិត្តពីលោកគ្រូអ្នកគ្រូ បុគ្គលិកអង្គការទស្សនៈពិភពលោក និងមេភូមិ នាងបានបោះជំហានចេញ ពីតំបន់សុខស្រួលរបស់នាង។
តាមរយៈការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ បំណិនជីវិត និងការសម្រុះសម្រួល រដ្ឋា បានផ្លាស់ប្រែ។

# នាងនិយាយថា៖ “ខ្ញុំលែងខ្លាចក្នុងការនិយាយក្នុងអង្គប្រជុំ បង្រៀនយុវជន ឬ ចូលរួមជាមួយអាជ្ញាធរទៀតហើយ”។

មិនយូរប៉ុន្មាន នាងបានដឹកនាំក្លឹបយុវជន និងសម្របសម្រួលគម្រោងសហគមន៍ ដែលទទួលបានការគាំទ្រថវិកាពីអង្គការទស្សនៈពិភពលោក អាជ្ញាធរមូលដ្ឋាន និងសហគមន៍ផ្ទាល់។ គម្រោងទាំងនេះ បានដោះស្រាយបញ្ហាជាក់ស្តែង ចាប់ពីកង្វះសម្ភារៈសិក្សារហូតដល់ការចូលរួមរបស់យុវជន ដែលបង្ហាញថាយុវជន អាចជំរុញឱ្យមានការផ្លាស់ប្រែ។

ការផ្លាស់ប្រែរបស់នាងមិនបានបញ្ឈប់ត្រឹមនេះទេ។ រដ្ឋា បានក្លាយជាគ្រូបង្រៀនភាសាអង់គ្លេសនៅសាលាឯកជនមួយ បញ្ចប់ថ្នាក់បរិញ្ញាបត្រ និងបច្ចុប្បន្នកំពុងបម្រើការងារជាគ្រូជាប់កិច្ចសន្យា នៅក្នុងសហគមន៍របស់នាង។ នាងក៏ដឹកនាំក្លឹបយុវជនក្នុងមូលដ្ឋាន និងរៀបចំជំរំចុងសប្តាហ៍សម្រាប់កុមារផងដែរ។ អាជ្ញាធរភូមិ និងថ្នាក់ដឹកនាំសាលាបានសរសើរការលះបង់របស់នាង៖ លោក ណយ ណាល់ ដែលជាមេភូមិ បានមានប្រសាសន៍ថា “ខ្ញុំរីករាយយ៉ាងខ្លាំងដែលបានឃើញយុវជនចេះជួយសហគមន៍បែបនេះ”។

សព្វថ្ងៃនេះ រដ្ឋា គឺជានិមិត្តរូបនៃភាពធន់ និងភាពជាអ្នកដឹកនាំ។ នាងនិយាយថា “អង្គការទស្សនៈពិភពលោកបានផ្លាស់ប្រែជីវិតរបស់ខ្ញុំ។ ខ្ញុំមានការអត់ធ្មត់ ភាពក្លាហាន ចំណេះដឹង និងជំនាញព្រមទាំងឱកាសកសាងអនាគតដ៏ល្អប្រសើរសម្រាប់ខ្លួនឯង និងសហគមន៍របស់ខ្ញុំ។”







# ដំណើររបស់ ឡុក ដារ៉ូ៖ ការផ្លាស់ប្តូរពីការដើរទៅរកក្តីសង្ឃឹម ទៅជាការជិះកង់ទៅរកក្តីស្រមៃរបស់នាង

## ការធាក់កង់ម្តងៗសុទ្ធតែមានអត្ថន័យ៖ តើកង់មួយគ្រឿងបានក្លាយជាស្ពានចម្លងទៅរកការអប់រំ និងក្តីស្រមៃយ៉ាងដូចម្តេច?

រឿងរ៉ាវរបស់ ឡុក ដារ៉ូ ចាប់ផ្តើមនៅក្នុងឃុំវឌ្ឍនៈដ៏ស្ងប់ស្ងាត់ នៃស្រុកសំបូរ ខេត្តក្រចេះ ជាទីដែលមានផ្លូវលំបត់បែនកាត់តាមវាលស្រែ ហើយប្រជាពលរដ្ឋកំពុងសម្ងំរស់នៅយ៉ាងអត់ធន់ក្រោមដំបូលផ្ទះនីមួយៗ។

ដារ៉ូ ដែលមានអាយុទើបតែ ៩ ឆ្នាំ មានភាពរឹងមាំពីខាងក្នុងខ្លួន ដូចអ្នកដែលធ្លាប់ប្រឈមមុខនឹងការលំបាកតាំងពីក្មេង។ ឪពុកម្តាយរបស់នាងបានបែកបាក់គ្នា នៅពេលនាងមានអាយុ ៥ ឆ្នាំ ហើយឪពុករបស់នាង បានចេញទៅធ្វើសំណង់នៅរាជធានីភ្នំពេញ និងមកលេងផ្ទះតែពីរបីដងប៉ុណ្ណោះក្នុងមួយឆ្នាំ។ ដោយគ្មានការគាំទ្រជាប្រចាំពីឪពុកម្តាយ ដារ៉ូ បានរកឃើញទីពឹងថ្មី គឺលោកពូ និងអ្នកមីងរបស់នាង ដែលពួកគាត់បាន ទទួលស្វាគមន៍នាង និងប្អូនប្រុសរបស់នាងឱ្យមករស់នៅក្នុងគ្រួសារដ៏សាមញ្ញមួយ ដែលពឹងផ្អែកលើការធ្វើកសិកម្ម នេសាទ និងការប្រមូលផលស្វាយចន្ទី និងដំឡូងមី។ ក្នុងជីវភាពរស់នៅរបស់ពួកគេ តម្រូវការមូលដ្ឋាន ដូចជា ទឹកស្អាត អាហារូបត្ថម្ភ និងអនាម័យ នៅតែជាបញ្ហាប្រឈម ប៉ុន្តែក្តីស្រឡាញ់ និងការតាំងចិត្តយ៉ាង ស្ងៀមស្ងាត់បានត្រួសត្រាយផ្លូវសម្រាប់ពួកគេជារៀងរាល់ថ្ងៃ។

ដារ៉ូ ត្រូវដើរជាងពីរគីឡូម៉ែត្រទៅសាលារៀនជារៀងរាល់ថ្ងៃ តាំងពីនាងអាយុ ៥ ឆ្នាំមកម្ល៉េះ។ ពេលខ្លះ នាងជិះកង់ជាមួយពូ ពេលខ្លះ ដើរជាមួយមិត្តភក្តិ។ នាងមិនដែលបណ្តោយឱ្យចម្ងាយផ្លូវរារាំងដល់ខ្លួនឯងឡើយ។

ការផ្លាស់ប្តូរបានចាប់ផ្តើមនៅឆ្នាំ ២០២៣។ កម្មវិធីតំបន់ស្រុកសំបូររបស់អង្គការទស្សនៈពិភពលោក បានដឹងពីស្ថានភាពរបស់ ដារ៉ូ និងចុះអន្តរាគមន៍។ មីងរបស់នាង ឈ្មោះ ស្បោង នឿន (អាយុ ៤៨ ឆ្នាំ) ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គជំរុញការចូលរួមរបស់សាលារៀន និងកិច្ចប្រជុំប្រចាំត្រីមាស តាមរយៈការសម្របសម្រួលជាមួយគណៈកម្មការទ្រទ្រង់សាលារៀន។ ការជួបជុំទាំងនេះបានលាតត្រដាង ពីអ្វីដែលកើតឡើង នៅក្នុង

ថ្នាក់រៀន ដោយបង្ហាញគាត់ពីអ្វីដែល ដារ៉ូ កំពុងរៀន និងវិធីពង្រឹងបន្ថែមការសិក្សានៅផ្ទះ។ គាត់បានចែករំលែកថា “ពីមុនខ្ញុំធ្លាប់គិតថា សាលារៀនគឺសម្រាប់តែលោកគ្រូអ្នកគ្រូប៉ុណ្ណោះ។ ឥឡូវនេះ ខ្ញុំដឹងថា ខ្ញុំក៏មានចំណែកនៅក្នុងនោះដែរ។”

ទោះបីជាមានការលំបាកផ្នែកសេដ្ឋកិច្ចខ្លាំងយ៉ាងណាក៏ដោយ ក៏មីងរបស់នាងនៅតែមានអារម្មណ៍មោទនភាព។ “ទោះបីជាយើងខ្វះខាតខ្លាំងក៏ដោយ ប៉ុន្តែខ្ញុំតែងតែគាំទ្រការសិក្សារបស់នាង ជំរុញនាងឱ្យធ្វើលំហាត់ គ្រូដាក់ឱ្យ និងរំឭកមេរៀន។ នោះគឺជាក្តីសង្ឃឹមរបស់យើងសម្រាប់ជីវិតដ៏ប្រសើរមួយដើម្បីឱ្យដារ៉ូទទួលបាន ការងារល្អ និងជួយខ្លួនឯង ព្រមទាំងប្អូនប្រុសរបស់នាង ដើម្បីកុំឱ្យនាងជួបការលំបាកដូចខ្ញុំ។”

ដោយឃើញ ដារ៉ូ មានការរីកចម្រើន អ្នកស្រី នឿន បានចាប់ផ្តើមចូលរួមកម្មវិធីសាលារៀន និងសិក្ខាសាលាសម្រាប់មាតាបិតា ដែលត្រូវបានសម្របសម្រួលដោយអង្គការទស្សនៈពិភពលោក ហើយក្នុងព្រឹត្តិការណ៍ទាំងនោះ គាត់តែងតែអបអរសាទរចំពោះវឌ្ឍនភាពរបស់ក្មួយស្រី។ កម្មវិធីនេះបានជួយឱ្យគាត់ក្លាយជាដៃគូសិក្សាដ៏មានទំនុកចិត្តនៅផ្ទះ ដែលចេះសួរសំណួរឆ្លុះបញ្ចាំង ចូលរួមស្តាប់ការនិទានរឿង និងកោតសរសើរការប្តេជ្ញាចិត្តរបស់ ដារ៉ូ។ មីង និងពូរបស់ ដារ៉ូ បានប្រែក្លាយផ្ទះរបស់ពួកគេ ទៅជាកន្លែងដែលជួយគាំទ្របន្ថែមដល់កុមារងាយរងគ្រោះទាំងនេះ។

ដោយត្រូវបានកំណត់អត្តសញ្ញាណជាកុមារងាយរងគ្រោះបំផុតនៅឆ្នាំ ២០២៤ ដារ៉ូ ទទួលបានការគាំទ្រ ចំគោលដៅពីកម្មវិធីរបស់អង្គការទស្សនៈពិភពលោក និងគម្រោងដៃគូរួមគ្នាផ្តល់ឱកាសដល់កុមារបាត់បង់ឱកាសនៅកម្ពុជា (CCOSC) មានដូចជា កង់មួយគ្រឿង និងសម្ភារៈសិក្សា ដែលបានផ្លាស់ប្តូរអ្វីៗទាំងអស់។ នាងញញឹម បណ្តើរនិយាយបណ្តើរថា “ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដែលទទួលបានកង់នេះ។ វាជួយខ្ញុំឱ្យទៅសាលារៀនបានលឿនជាងមុន ជាមួយប្អូនប្រុសរបស់ខ្ញុំ ហើយខ្ញុំនឹងថែរក្សាវាឱ្យបានល្អ។”

សព្វថ្ងៃនេះ ដារ៉ូ ជិះកង់ឆ្ពោះទៅសាលារៀន និងអនាគតរបស់នាង។ នៅក្នុងថ្នាក់ នាងមានភាពលេចធ្លោតាមរយៈការអានអត្ថបទភាសាខ្មែរ ការប្រកួតការលេងកម្សាន្ត សកម្មភាពសម្តែងតួ និងការច្រៀង ជាពិសេសក្នុងម៉ោងសិក្សាដែលដឹកនាំដោយអ្នកគ្រូរបស់នាង គឺអ្នកស្រី គង់ ស៊ីនឿន។ នៅផ្ទះនាងជួយមើលប្អូនប្រុសរបស់នាង ជួយធ្វើម្ហូប និងរៀបចំកន្លែងរស់នៅរបស់នាងឱ្យមានសណ្តាប់ធ្នាប់ល្អ។

អ្នកគ្រូរបស់នាងបានលើកឡើងថា “ឥឡូវនេះ គ្រួសាររបស់នាងបានបង្ហាញទំនាក់ទំនងយ៉ាងរឹងមាំ ជាមួយសាលារៀន។ ពួកគាត់មិនដែលខកខានកិច្ចប្រជុំឡើយ លុះត្រាតែមានការងារសំខាន់។ ពួកគាត់គាំទ្រ ដារ៉ូ ទាំងផ្លូវកាយ និងផ្លូវចិត្ត ហេតុនេះហើយទើបការសិក្សារបស់នាងប្រសើរឡើងជាលំដាប់។ នាងទទួលបានចំណាត់ថ្នាក់លេខ ៩ នៅក្នុងថ្នាក់។”

ជំរំអំណានបានបន្តពង្រឹងជំនាញអក្ខរកម្ម និងទំនុកចិត្តរបស់នាងបន្ថែមទៀត ដោយបង្កើតឱ្យមាន ពេលវេលាសិក្សាដ៏រីករាយ ដែលនាងទទួលបានលើសពីការរៀននៅក្នុងថ្នាក់។ ដារ៉ូរស់នៅក្នុងជីវិតដែល ងាយរងគ្រោះ ប៉ុន្តែក៏ពោរពេញដោយជ័យជម្នះយ៉ាងស្ងៀមស្ងាត់ផងដែរ។ អ្វីដែលធ្វើឱ្យនាងមានភាពលេចធ្លោ មិនមែនត្រឹមតែនាមជាកុមារងាយរងគ្រោះបំផុតនោះទេ ប៉ុន្តែជាក្តីរីករាយដែលនាងទទួលបានពីការអានភាសាខ្មែរ ស្មារតីសប្បុរសរបស់នាងចំពោះមិត្តភក្តិ និងក្តីស្រមៃដ៏មុតមាំរបស់នាងដែលចង់ក្លាយជាគ្រូបង្រៀនម្នាក់។ “ខ្ញុំចង់ជួយកុមារបន្ថែមទៀតនៅក្នុងសហគមន៍របស់ខ្ញុំឱ្យទទួលបានចំណេះដឹងកាន់តែប្រសើរ”។

ដំណើររបស់នាង មិនមែនជាដំណើរដែលនាងត្រូវដើរតែម្នាក់ឯងនោះទេ។ ក្រោមការគាំទ្រពីអ្នកថែទាំ លោកគ្រូអ្នកគ្រូ និងកម្មវិធីចម្រុះរបស់អង្គការទស្សនៈពិភពលោក ដារ៉ូ អាចបោះជំហានទៅមុខប្រកប ដោយសេចក្តីថ្លៃថ្នូរ ភាពធន់ និងគោលដៅច្បាស់លាស់។ ការណ៍ដែលនាងធាក់កង់ម្តងៗ មិនមែនគ្រាន់តែជាការធ្វើ ដំណើរទៅសាលារៀននោះទេ ប៉ុន្តែគឺជាការធ្វើដំណើរឆ្ពោះទៅរកក្តីស្រមៃដែលនាងកំពុងតែកសាងឡើង។





# ទិដ្ឋភាពទូទៅឆ្នាំ ២០២៥...

**យើងបានបម្រើប្រជាពលរដ្ឋនៅក្នុង ៨៤% នៃខេត្ត ក្រុងរបស់ប្រទេសកម្ពុជា (ស្មើនឹង ២០ ខេត្ត) និងរាជធានីភ្នំពេញ ដោយគ្របដណ្តប់លើ ៦៥% នៃឃុំ សង្កាត់សរុបចំនួន ១.០៧១។**



# ក្នុងឆ្នាំ ២០២៥
# យើងបានគ្របដណ្ដប់ដល់...

## ប្រជាពលរដ្ឋ
## ៥,៤ លាននាក់

**ស្មើនឹង ៣១% នៃចំនួនប្រជាពលរដ្ឋកម្ពុជាសរុប**

**រួមទាំង**

## ក្មេងស្រី និងក្មេងប្រុស
## ៣,១ លាននាក់

**ក្នុងនោះ ៧៧% ជាកុមារងាយរងគ្រោះបំផុត នៅកម្ពុជា**

## តាមរបៀបណា...

តាមរយៈការបង្កើតឱកាស ដែលផ្លាស់ប្ដូរជីវិត

តាមរយៈការកសាងភាពជាដៃគូប្រកបដោយអត្ថន័យ សម្រាប់អនាគតរបស់ពួកគេ

តាមរយៈការធានាបាននូវបរិស្ថាន ប្រកបដោយសុវត្ថិភាព ដែលពួកគេអាចរីកចម្រើន

តាមរយៈការពង្រឹងប្រព័ន្ធ ដែលអាចឱ្យពួកគេចូលរួម ប្រកបដោយអត្ថន័យ

*អង្គការទស្សនៈពិភពលោកទទួលស្គាល់ថា កុមារដែលងាយរងគ្រោះបំផុត គួរតែមានជីវិតល្អប្រសើរ និងសមត្ថភាពអភិវឌ្ឍខ្លួន ដើម្បីសម្រេចបានសក្តានុពលពេញលេញរបស់ពួកគេ ទោះបីជាពួកគេរងផល ប៉ះពាល់ខ្លាំងជាងគេដោយការខ្វះខាតខ្លាំង និង ការរំលោភសិទ្ធិក៏ដោយ។ កុមារទាំងនេះច្រើនតែរស់នៅក្នុង ស្ថានភាពគ្រោះមហន្តរាយ និងទំនាក់ទំនងដែលពោរពេញ ដោយអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនអើពើ និងការរើសអើង។

# ទិដ្ឋភាពទូទៅឆ្នាំ ២០២៥...

**ជំនាញបច្ចេកទេសរបស់យើងបានគ្របដណ្ដប់ លើវិស័យអាទិភាពនៅកម្ពុជា ដូចខាងក្រោម...**

- សុខភាព និងអាហារូបត្ថម្ភ
- គណនេយ្យភាពសង្គម
- កិច្ចការពារកុមារ និង ការចូលរួម
- ការអប់រំបរិយាបន្ន
- ភាពធន់នឹងការប្រែប្រួលអាកាសធាតុ
- ទឹកស្អាត និងអនាម័យ (WASH)
- ការឆ្លើយតបបន្ទាន់ផ្នែកមនុស្សធម៌ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ការចិញ្ចឹមជីវិតប្រកបដោយចីរភាព
- សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)

## ...ដែលរួមចំណែកដោយផ្ទាល់ដល់

**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១**
របស់រាជរដ្ឋាភិបាលកម្ពុជា




១ ការអភិវឌ្ឍមូលធនមនុស្ស
ការកែទម្រង់ និងការពង្រឹងស្ថាប័ន

២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែងការកែលម្អធនធានមនុស្ស និងប្រសិទ្ធភាពការងារ

៣ ការអភិវឌ្ឍវិស័យឯកជន និងការងារ
ការលើកកម្ពស់ និងការពង្រឹងគណនេយ្យភាព និងសុចរិតភាពក្នុងរដ្ឋបាលសាធារណ:

៤ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌

៥ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល
ការពង្រឹងអភិបាលកិច្ចនៃវិស័យឯកជន និងធុរកិច្ច

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព**
របស់អង្គការសហប្រជាជាតិ



# ដើម្បីកុមារ

## សមិទ្ធផលសំខាន់ៗនៃសុខុមាលភាពកុមារក្នុងឆ្នាំ ២០២៥



# កិច្ចការពារកុមារ និងការចូលរួម

**ការធានាថា កុមារគ្រប់រូបត្រូវបានការពារ ពីគ្រប់ទម្រង់នៃអំពើហិង្សា និងចូលរួមក្នុងការសម្រេចចិត្តនានា។**

- ការបណ្តុះបណ្តាលបំណិនជីវិត
- គម្រោងសហគមន៍ដឹកនាំដោយយុវជន
- ការអភិវឌ្ឍសមត្ថភាពដៃគូក្នុងមូលដ្ឋាន
- មាតិកាដែលដឹកនាំដោយក្មេងជំទង់
- ការបណ្តុះបណ្តាលសម្រាប់មាតាបិតា/អ្នកថែទាំ

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**២២៦.២៦២**

ការគ្របដណ្តប់ដល់ប្រជាពលរដ្ឋចំនួន ២២៦.២៦២ នាក់ (កុមារី ១១៦.៣៦៥ នាក់) ក្នុងនោះ មានកុមាររងាររងគ្រោះបំផុតចំនួន ១៨៤.២៣០ នាក់ (កុមារី ៩១.៦៦៣ នាក់) តាមរយៈកម្មវិធីកិច្ចការពារកុមារ និងការចូលរួមរបស់យើងនៅទូទាំងប្រទេសកម្ពុជា។

**៩៨,២០%**

ទទួលបានចំណេះដឹង និងជំនាញវិជ្ជាជីវៈ (ស្រី ៥២,២៥%)។

**៤២.០៩៤**

យុវជនចំនួន ៤២.០៩៤ នាក់បានចូលរួមក្នុងគម្រោង និងយុទ្ធនាការដែលដឹកនាំដោយយុវជន។

**៧៧,៤៨%**

យុវជន ៧៧,៤៨% ទទួលបានការងារមានប្រាក់ឈ្នួល បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល។

**៨.៦៥៣**

មាតាបិតា/អ្នកថែទាំចំនួន ៨.៦៥៣ នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីវិន័យវិជ្ជមាន។

**១០៩**

ឃុំ/សង្កាត់ចំនួន ១០៩ បានបញ្ចូលកិច្ចការពារកុមារទៅក្នុងកម្មវិធីវិនិយោគឃុំ/សង្កាត់។






### ការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥

16 PEACE, JUSTICE AND STRONG INSTITUTIONS

រៀងរាល់ ២៤ ម៉ោងម្តង មាតាបិតាថ្មីចំនួន ២៨ នាក់បានទទួលការបណ្តុះបណ្តាល ដើម្បីការពារកុមារពីការ រំលោភបំពាន ការកេងប្រវ័ញ្ចការជួញដូរ និងអំពើហិង្សា។



សក្កដា ចូលរៀននៅថ្នាក់រៀនបណ្ដោះអាសន្នដែលបង្កើតឡើង ដើម្បីជួយឱ្យកុមារបានបន្តការសិក្សារបស់ពួកគេ ក្នុងពេលដែលសាលារៀនធម្មតាបន្តបិទទ្វារនៅតាមទីតាំងភៀសសឹក។

# ការអប់រំបរិយាបន្ន

## ការបង្កើនចំនួនកុមារដែលត្រូវបានបំពាក់បំប៉នអក្ខរកម្មប្រកបដោយគុណភាពសម្រាប់ជីវិត។

- ការបណ្ដុះបណ្ដាលគ្រូបឋមសិក្សា
- កម្មវិធីផ្ដល់អាហារតាមសាលារៀន
- ជំរឹអំណាន
- ការចែកសៀវភៅ និងសម្ភារៈសិក្សា
- ការចូលរួមរបស់អ្នកថែទាំ និងសហគមន៍
- ការចុះឈ្មោះកុមារក្រៅសាលាឱ្យបានចូលរៀន
- ការអនុវត្តក្របខណ្ឌគណនេយ្យភាពសាលារៀន

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**១៦៤.៩៤៩**

កុមារចំនួន ១៦៤.៩៤៩ នាក់បានចូលរួមក្នុងកម្មវិធីការអប់រំបរិយាបន្នរបស់យើង។

**៨៩%**

អ្នកចូលរួម ៨៩% (កុមារ ១៤៣.២៧២ នាក់) មកពីគ្រួសារងាយរងគ្រោះបំផុត។

**៥.០២៦**

កង់ចំនួន ៥.០២៦ គ្រឿងត្រូវបានចែកជូនកុមារដែលរស់នៅឆ្ងាយពីសាលារៀន ដើម្បីសម្រួលដល់ការធ្វើដំណើរប្រចាំថ្ងៃរបស់ពួកគេ និងមានសុវត្ថិភាពជាងមុន។

**៦១%**

សាលារៀន ៦១% (៤០៣ សាលារៀន) មានបរិយាកាសសិក្សាកាន់តែប្រសើរឡើង។

**២០.០១៩**

សម្ភារៈសិក្សាចំនួន ២០.០១៩ កញ្ចប់ត្រូវបានចែកជូនកុមារមកពីគ្រួសារក្រីក្រ ដើម្បីលើកកម្ពស់ការអប់រំ និងសុខុមាលភាពរបស់ពួកគេ។

**៨**

អគារសិក្សាចំនួន ៨ ស្មើនឹង ៣៤ បន្ទប់ និងបង្គន់អនាម័យចំនួន ២ ស្មើនឹង ១០ បន្ទប់ ត្រូវបានសាងសង់ឡើង ដើម្បីបង្កើតឱ្យមានកន្លែងសិក្សាដែលប្រកបដោយសុវត្ថិភាព និងបរិយាបន្ន។

**១៩.៤០០**

កុមារបាត់បង់ឱកាស ចំនួន ១៩.៤០០ នាក់ មានលទ្ធភាពទទួលបានការអប់រំឡើងវិញជាមួយអង្គការ Action Education។

### ការរួមចំណែកដោយផ្ទាល់ដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥

4 QUALITY EDUCATION

រៀងរាល់ ៦០ នាទីម្ដង កុមារចំនួន ២២ នាក់បានចូលរួមក្នុងសកម្មភាពលើកកម្ពស់អក្ខរកម្ម

# សុខភាព និងអាហារូបត្ថម្ភ

**ការបង្កើនលទ្ធភាពទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភ និងការលើកកម្ពស់ឥរិយាបថសុខភាពល្អ ក្នុងចំណោមស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ ឆ្នាំ**

- ការថែទាំ និងការអភិវឌ្ឍកុមារតូច
- ការផ្លាស់ប្តូរឥរិយាបថជាមួយម្តាយ និងជីដូន
- កម្មវិធីផ្តល់អាហារតាមសាលារៀន
- ការកំណត់អត្តសញ្ញាណ និងការបញ្ជូនកុមារខ្វះអាហារូបត្ថម្ភទៅទទួលសេវា
- ការព្យាបាលវេជ្ជសាស្ត្រ
- ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម
- ការលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**៤១.៨៨៧**

កុមារអាយុ ០-៥ ឆ្នាំចំនួន ៤១.៨៨៧ នាក់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីសុខភាព និងអាហារូបត្ថម្ភរបស់យើងនៅទូទាំងប្រទេសកម្ពុជា។

**២២.០០៩**

ស្ត្រីដល់វ័យបន្តពូជចំនួន ២២.០០៩ នាក់ ត្រូវបានចុះផ្សព្វផ្សាយ ដោយបុគ្គលិកសុខាភិបាល សហគមន៍ដែលបានទទួលការបណ្តុះបណ្តាល។

**១៦.០៧៧**

សិស្សចំនួន ១៦.០៧៧ នាក់ មកពីសាលាបឋមសិក្សាគោលដៅចំនួន ៧៥ ក្នុងស្រុក ៣ នៃខេត្តកំពង់ធំ ទទួលបានអាហារនៅសាលារៀនជាប្រចាំថ្ងៃ។

**២៨.១៨៩**

មាតាបិតា/អណាព្យាបាលចំនួន ២៨.១៨៩ នាក់ បានចូលរួមក្នុងវគ្គផ្សព្វផ្សាយការយល់ដឹងអំពីសុខភាព និងអាហារូបត្ថម្ភ។

**១.១៥០**

កុមារចំនួន ១.១៥០ នាក់ ត្រូវបានពិនិត្យរកបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាល់ និងត្រូវបានម្តាយ/អ្នកថែទាំបញ្ជូនទៅមូលដ្ឋានសុខាភិបាលសមស្របដែលនៅជិតបំផុត ដោយប្រើឧបករណ៍ស្ទង់ដារ វាស់ជុំវិញពាក់កណ្តាលដើមដៃ (MUAC)។



បុគ្គលិកសុខភាពសហគមន៍ជួយគាំទ្រគ្រួសារមួយតាមរយៈការពិនិត្យការលូតលាស់របស់កុមារជាប្រចាំ ក្នុងអំឡុងពេលចុះសួរសុខទុក្ខដល់ផ្ទះ។

### ការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥

3 GOOD HEALTH AND WELL-BEING

រៀងរាល់ ២៤ ម៉ោងម្តង កុមារចំនួន ៩២ នាក់ (អាយុ ០-៥ ឆ្នាំ) ត្រូវបានវាយតម្លៃ និងគាំទ្រ ដោយបុគ្គលិកថែទាំសុខភាពសហគមន៍ដែលបានទទួលការបណ្តុះបណ្តាល។




# ការចិញ្ចឹមជីវិតដែលប្រកបដោយចីរភាព និងធន់នឹងអាកាសធាតុ

**ការបង្កើនប្រាក់ចំណូលរបស់គ្រួសារដែលងាយរងគ្រោះបំផុត ដើម្បីកសាងភាពធន់របស់ពួកគេទៅនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ។**

ការបណ្តុះបណ្តាលស្តីពីកសិកម្មឆ្លាតវៃធន់នឹងអាកាសធាតុ | ការបណ្តុះបណ្តាលស្តីពីសហគ្រិនភាពធុរកិច្ច

ក្រុមអ្នកផលិត | ការបណ្តុះបណ្តាលស្តីពីអក្ខរកម្មហិរញ្ញវត្ថុ | ក្រុមសន្សំ

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

### ២០.៧២២

ប្រជាពលរដ្ឋចំនួន ២០.៧២២ នាក់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីកសាងរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (BSL) របស់អង្គការទស្សនៈពិភពលោក។

### ២.៨២៩

ប្រជាពលរដ្ឋចំនួន ២.៨២៩ នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មឆ្លាតវៃធន់នឹងអាកាសធាតុ និងប្រកបដោយចីរភាព ដែលបានកែលម្អ។

### ២.៣៧៥

ស្ត្រីចំនួន ២.៣៧៥ នាក់ បានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូល។

### ២.៥៩៩

ប្រជាពលរដ្ឋចំនួន ២.៥៩៩ នាក់ បានបង្កើនជំនាញធុរកិច្ច/សហគ្រិនភាពរបស់ពួកគេ។

### ២.៤៨៨

ប្រជាពលរដ្ឋចំនួន ២.៤៨៨ គ្រួសារ បានបង្កើនចំណេះដឹងហិរញ្ញវត្ថុរបស់ពួកគេ។

**ការរួមចំណែកដោយផ្ទាល់ដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥**

1 NO POVERTY

រៀងរាល់ ២៤ ម៉ោងម្តង កសិករចំនួន ១០ នាក់ បានទទួលការបណ្តុះបណ្តាល និងធនធាន ដើម្បីកែលម្អបច្ចេកទេសកសិកម្មឆ្លាតវៃធន់នឹងអាកាសធាតុ និងប្រកបដោយចីរភាព។

# ទឹកស្អាត និងអនាម័យ (WASH)

**ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងឥរិយាបថ ដើម្បីធានាការបរិភោគទឹកស្អាត និងការអនុវត្តអនាម័យល្អ។**

ការផ្លាស់ប្តូរឥរិយាបថសង្គមតាមរយៈការប្រាស្រ័យទាក់ទង (SBCC) | ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ (WASH) | ការលើកកម្ពស់ការប្រើប្រាស់បង្គន់អនាម័យ | ការបង្កើតគណៈកម្មការទឹកស្អាត និងអនាម័យក្នុងមូលដ្ឋាន | វិធីសាស្ត្រចម្រោះទឹកផឹក

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**៦៧.០៦៦**

កុមារចំនួន ៦៧.០៦៦ នាក់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីទឹកស្អាត និងអនាម័យ (WASH)។

**៣០.៨៥៧**

ប្រជាពលរដ្ឋចំនួន ៣០.៨៥៧ នាក់ ទទួលបានសេវាអនាម័យកម្រិតមូលដ្ឋាន។

**៣០.៤០៣**

ប្រជាពលរដ្ឋចំនួន ៣០.៤០៣ នាក់ ទទួលបានសេវាទឹកផឹកកម្រិតមូលដ្ឋាន។

**៧៧**

អណ្តូងស្នប់ចំនួន ៧៧ ត្រូវបានតម្លើងរួចរាល់ និងដាក់ឱ្យប្រើប្រាស់នៅក្នុងសហគមន៍។

**៤៥១**

សហគមន៍ចំនួន ៤៥១ ត្រូវបានទទួលស្គាល់ជាសហគមន៍បញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល (ODF)។

**៦៨.៤៤២**

ប្រជាពលរដ្ឋចំនួន ៦៨.៤៤២ នាក់ ទទួលបានកញ្ចប់អនាម័យ។

**៦.៥៥៤**

ប្រជាពលរដ្ឋ ៦.៥៥៤ គ្រួសារ បានសាងសង់បង្គន់អនាម័យរួចរាល់។

**៨០**

គណៈកម្មការទឹកស្អាត និងអនាម័យចំនួន ៨០ ត្រូវបានបង្កើតឡើង ឬដំណើរការឡើងវិញ និងទទួលបានការបណ្តុះបណ្តាល រួមជាមួយនឹងការបង្កើតប្រព័ន្ធកៀរគរធនធានសម្រាប់ការថែទាំ និងជួសជុល។




**ការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥**

6 CLEAN WATER AND SANITATION

រៀងរាល់ ៦០ នាទីម្តង មានប្រជាពលរដ្ឋ ២ នាក់បន្ថែមទៀតទទួលបានសេវាទឹកផឹកកម្រិតមូលដ្ឋាន។



# ការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ

**ការធានាថា បុគ្គល គ្រួសារ និងសហគមន៍កាន់តែមានភាពធន់ទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ**

ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ | ការរៀបចំផែនការកាត់បន្ថយហានិភ័យ | ការទប់ស្កាត់គ្រោះមហន្តរាយ

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**១.៧១០**

ប្រជាពលរដ្ឋចំនួន ១.៧១០ នាក់ រួមទាំងកុមារ បានទទួលការបណ្តុះបណ្តាលស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

**៨**

សាលារៀនចំនួន ៨ សម្រេចបានបរិស្ថានសាលារៀនមានសុវត្ថិភាព។

**៣៧**

សហគមន៍ចំនួន ៣៧ បានអនុវត្តសកម្មភាពកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**៦១%**

ក្នុងចំណោមគ្រួសារដែលប្រឈមនឹងគ្រោះមហន្តរាយ មានគ្រួសារ ៦១% អាចស្តារឡើងវិញ និងបច្ចុប្បន្ន កំពុងរស់នៅក្នុងកម្រិតជីវភាពដូចមុនពេលមានគ្រោះមហន្តរាយ។

**ការរួមចំណែកដោយផ្ទាល់ដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០២៥**

11 SUSTAINABLE CITIES AND COMMUNITIES

រៀងរាល់ ២៤ ម៉ោងម្តង មានមនុស្សចំនួន ៣០ នាក់បន្ថែមទៀត បានទទួលការបណ្តុះបណ្តាលស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។




# ដើម្បី ការផ្លាស់ប្រែ

សមិទ្ធផលសំខាន់ៗនៃការពង្រឹង
ប្រព័ន្ធក្នុងមូលដ្ឋាន ក្នុងឆ្នាំ ២០២៥



# ការអភិវឌ្ឍប្រកបដោយបរិយាបន្ន

**ការធានាថា សំឡេងទាំងអស់ត្រូវបានស្តាប់ឮ និងមានតម្លៃនៅក្នុងការឈានទៅសម្រេចបានគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាព និងដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ របស់កម្ពុជា។**

- ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF)
- ការចូលរួមរបស់សហគមន៍
- កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C)
- ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**៣.១៦៥.២៦៧**

ប្រជាពលរដ្ឋចំនួន ៣.១៦៥.២៦៧ នាក់ (ស្រី ៥១%) ទទួលបានផលជះពីការ អនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) នៅក្នុង ២០ ខេត្ត ក្រុង និង រាជធានីភ្នំពេញ។

**៩៧៦**

ឃុំ/សង្កាត់ចំនួន ៩៧៦ បានបែងចែកថវិកាឃុំ/សង្កាត់ចំនួន ៨០៨.៦៤៥ ដុល្លារអាមេរិក ដើម្បីគាំទ្រ ដល់ការអនុវត្តគណនេយ្យភាពសង្គម។

**៩១%**

អ្នកផ្តល់សេវាចំនួន ៩១% សម្រេចបានស្តង់ដារជាតិសំខាន់ៗក្នុងវិស័យសុខាភិបាល អប់រំ និងរដ្ឋបាល។

**៧២%**

ប្រជាពលរដ្ឋចំនួន ៧២% យល់ដឹងពីសិទ្ធិរបស់ពួកគេ និងស្តង់ដារសេវាសាធារណៈដែលបានរំពឹងទុក។

**២៣.៧៦៦**

សកម្មភាពក្នុងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ចំនួន ២៣.៧៦៦ ត្រូវបានអនុវត្តដោយអ្នកផ្តល់សេវា។

# ការអភិវឌ្ឍប្រកបដោយបរិយាបន្ន

សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)

សហគ្រិនភាពរបស់ស្ត្រី

ការផ្លាស់ប្តូរឥរិយាបថសង្គមតាមរយៈការប្រាស្រ័យទាក់ទង (SBCC)

ការងារអន្តរជំនឿសម្រាប់បរិយាបន្នពិការភាព

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

**៨៦%**

ស្ត្រីដល់វ័យបន្តពូជ (១៥-៤៩ ឆ្នាំ) ចំនួន ៨៦% មិនចង់មានកូន (បន្ថែម) ឬចង់ពន្យារកំណើតកូនបន្ទាប់ ហើយបច្ចុប្បន្ន កំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប។

**៩៦%**

គ្រួសារ ៩៦% មានស្ត្រីចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្ត។

**៥៥%**

សមាជិកសហគមន៍ (ក្មេងជំទង់ និងមនុស្សពេញវ័យ) ចំនួន ៥៥% គាំទ្រឥរិយាបថប្រកបដោយសមភាពយេនឌ័រ។

**១០.៧៥២**

ជនមានពិការភាពសរុបចំនួន ១០.៧៥២ នាក់ បានចូលរួមក្នុងកម្មវិធីរបស់យើង។

**៤.៤៥២**

ស្រីមានពិការភាពចំនួន ៤.៤៥២ នាក់ បានចូលរួមក្នុងកម្មវិធីរបស់យើង។

**៥.២០៩**

កុមារមានពិការភាព (អាយុក្រោម ១៨ ឆ្នាំ) សរុបចំនួន ៥.២០៩ នាក់ បានចូលរួមក្នុងកម្មវិធីរបស់យើង។



# ការតស៊ូមតិ

**យុទ្ធនាការ “ENOUGH”**

ទោះបីមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះក៏ដោយ ក៏កង្វះអាហារូបត្ថម្ភកុមារ នៅតែជាបញ្ហាកង្វល់សម្រាប់សុខភាព និងវិបុលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ ដោយមាន កុមារចំនួន ៩,៦% កំពុងជួបប្រទះបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាល់ (ការស្គមស្គាំង) ចាំបាច់ត្រូវមាន កិច្ចខិតខំប្រឹងប្រែងរួមគ្នា នៅទូទាំងប្រទេសកម្ពុជា ដើម្បីបញ្ចប់ការគំរាមកំហែងនេះដល់ ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ ដោយ សហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ អង្គការទស្សនៈពិភពលោក បានចាប់ផ្តើម យុទ្ធនាការ ENOUGH ដែលជាយុទ្ធនាការជាសកលនៅកម្ពុជាក្នុងឆ្នាំ ២០២៤ ក្រោមទស្សនវិស័យ “អាហារគ្រប់គ្រាន់សម្រាប់កុមារទាំងអស់នៅប្រទេសកម្ពុជា”។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

### ៧

ការផ្លាស់ប្តូរគោលនយោបាយចំនួន ៧ នៅថ្នាក់ជាតិ ៖ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ ២០២៥-២០៣០ | យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី ៣ ឆ្នាំ ២០២៤-២០២៨ | សារាចរអន្តរក្រសួងលេខ ០០៧ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។

### ៩

ការស្រាវជ្រាវ ៩ លើក ដឹកនាំដោយកុមារ/យុវជនស្តីពីកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ និងអាហារតាមសាលារៀន | លទ្ធផលរកឃើញពីការស្រាវជ្រាវទាំងនេះមានគោលបំណងតស៊ូមតិនៅក្នុង កិច្ចសន្ទនាសហគមន៍ នៃវេទិកា និងពិព័រណ៍កសិកម្មកម្ពុជាឆ្នាំ ២០២៥ (CAFE25) និងសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី ៣ នៅខេត្តកំពង់ធំ។

### ៥

ព្រឹត្តិការណ៍ថ្នាក់ក្រោមជាតិចំនួន ៥ ដើម្បីប្រកាសដាក់ឱ្យដំណើរ ការជាផ្លូវការនូវយុទ្ធនាការ ENOUGH ក្រោមកិច្ចសហការជាមួយរដ្ឋបាលខេត្ត ដោយមានប្រជាពលរដ្ឋប្រមាណ ៩១.៧០០ នាក់ បានចូលរួមដោយប្រយោល និងទទួលបានសារពីការដើរហែរក្បួនទ្រង់ទ្រាយធំនៅក្នុងទីរួមខេត្តទាំងប្រាំ។

### ៤៧

យុវជន និងសហគមន៍កសិកម្មចំនួន ៤៧ បានចូលរួមក្នុងការបង្កើនសំឡេងអំពីយុទ្ធនាការ ENOUGH និងអាហារតាមសាលារៀន។

### ២០

អ្នកផលិតមាតិកា និងអ្នកមានឥទ្ធិពលក្នុងបណ្តាញសង្គមចំនួន ២០ នាក់ បានចូលរួមក្នុងការជួបជុំអ្នកផលិតមាតិកាយុទ្ធនាការ ENOUGH ស្តីពីអាហារូបត្ថម្ភ និងការជ្រើសរើស អាហារល្អសម្រាប់សុខភាព ដោយបង្កើនសំឡេង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការជ្រើសរើសអាហារ និងអាហារូបត្ថម្ភ។







# ការតស៊ូមតិ

៤

អនុស្សរណៈនៃការយោគយល់គ្នា (MoUs) ចំនួន ៤ ត្រូវបានចុះហត្ថលេខាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MFAIC) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងក្រសួងសុខាភិបាល (MoH)។

១០

កិច្ចព្រមព្រៀងភាពជាដៃគូចំនួន ១០ ត្រូវបានចុះហត្ថលេខាជាមួយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ។

៤០

ក្រុមការងាររបស់យើងបានចូលរួមក្នុងក្រុមការងារបច្ចេកទេស និងវេទិកាថ្នាក់ជាតិចំនួន ៤០។

១៨

កិច្ចព្រមព្រៀងភាពជាដៃគូចំនួន ១៨ ត្រូវបានចុះហត្ថលេខាជាមួយដៃគូសាជីវកម្ម ដើម្បីគាំទ្រដល់ សុខុមាលភាពរបស់កុមារ និងគ្រួសារនៅកម្ពុជា។

៣

បុគ្គលិកអង្គការទស្សនៈពិភពលោកចំនួន ៣ នាក់ បានក្លាយជាគ្រូបង្គោលថ្នាក់ជាតិជាមួយ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

#រឿងរ៉ាវ



# ដំណើរនៃការផ្លាស់ប្រែ៖ តើគណនេយ្យភាពសង្គមបានផ្លាស់ប្រែមណ្ឌលសុខភាព ស្វាយតាយាន យ៉ាងដូចម្ដេច?

## ការជំរុញការផ្លាស់ប្រែតាមរយៈសំឡេង៖ ការផ្លាស់ប្រែនៃមណ្ឌលសុខភាព ស្វាយតាយាន

"កាលពីមុន មណ្ឌលសុខភាព (ស្វាយតាយាន) មានអគារចាស់មួយដែលបានបើកដំណើរការតាំងពីឆ្នាំ ១៩៩៨ មកម្ល៉េះ ដែលមិនស្របតាមស្តង់ដារ មិនមានឃ្លាំងស្តុកថ្នាំ និងមានបន្ទប់ទឹកប្រើរួមគ្នាតែមួយប៉ុណ្ណោះ (សម្រាប់បុរស និងស្ត្រី)។ ការផ្តល់សេវាមានភាពខ្វះចន្លោះ ដោយស្ថិតិបានបង្ហាញថា ក្នុងមួយខែៗ មានប្រជាពលរដ្ឋប្រមាណត្រឹមតែ ២៥០-៣០០ នាក់ប៉ុណ្ណោះ ដែលទទួលបានសេវា"។ នេះបើតាមការពន្យល់របស់លោក ចាន់ បូរ៉ាន់ ប្រធានមណ្ឌលសុខភាព ស្វាយតាយាន។ លោកបានបន្ថែមទៀតថា បញ្ហាប្រឈម មានដូចជា "ចំនួនបុគ្គលិកមិនគ្រប់គ្រាន់ ឥរិយាបថខ្វះវិជ្ជាជីវៈ អាកប្បកិរិយាច្រងេងច្រងាង និងការប្រើប្រាស់ពាក្យ សម្តីមិនសមរម្យចំពោះអតិថិជន និងគ្មានបុគ្គលិកប្រចាំការជាប់លាប់ក្នុងម៉ោងធ្វើការផ្លូវការ"។

អ្វីៗបានចាប់ផ្តើមផ្លាស់ប្តូរនៅដើមឆ្នាំ ២០២៣ ដោយការបើកទំព័រថ្មីមួយលេចឡើងនៅពេលដែលលោក បូរ៉ាន់ ឡើងកាន់តំណែងជាប្រធានមណ្ឌលសុខភាពនេះ ហើយអង្គការស្តារកម្ពុជាបានណែនាំពីការអនុវត្ត ក្របខណ្ឌ គណនេយ្យភាពសង្គម (ISAF)។ ISAF មានគោលបំណងធ្វើឱ្យសេវាសាធារណៈ ជាពិសេស មណ្ឌលសុខភាព សាលារៀន និងរដ្ឋបាលឃុំ កាន់តែមានតម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការ ប្រជាពលរដ្ឋ។ តាមរយៈប័ណ្ណដាក់ ពិន្ទុសហគមន៍ កិច្ចប្រជុំទល់មុខ និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាព (ផ.ស.រ.គ) ទីបំផុត សំឡេងដែលធ្លាប់តែស្ងៀមស្ងាត់ជាយូរមក ហើយ ត្រូវបានគេស្តាប់ឮ។

មតិកែលម្អរបស់សហគមន៍បានបង្ហាញពីបញ្ហាចាក់ឫសយ៉ាងជ្រៅ៖ ម៉ោងធ្វើការមិនទៀងទាត់ អនាម័យ ខ្សោយ កង្វះគណនេយ្យភាព និងគ្មានព័ត៌មានច្បាស់លាស់អំពីតម្លៃសេវា ឬថវិកា។ ការសន្ទនាទាំងនេះបានជំរុញឱ្យ មានសកម្មភាព។ មណ្ឌលសុខភាពនេះបានចាប់ផ្តើមរៀបចំដំណើរការរបស់ខ្លួនឡើងវិញ ធ្វើឱ្យឯកសារ មានភាពសាមញ្ញ និងធានាបាននូវការព្យាបាលស្មើភាពគ្នាសម្រាប់អ្នកជំងឺទាំងអស់ ដោយមិនប្រកាន់ថាមាន ឬក្រ

មាន ឬគ្មានប័ណ្ណសមធម៌សុខាភិបាលឡើយ។ បុគ្គលិកបាន ប្ដេជ្ញាធ្វើប្រតិបត្តិការ ២៤ ម៉ោងលើ ២៤ ម៉ោង ចូលរួមកិច្ចប្រជុំជាប្រចាំ និងប្រព្រឹត្តចំពោះអ្នកជំងឺដោយការគោរព និងសេចក្ដីថ្លៃថ្នូរ។

មិនយូរប៉ុន្មាន ការផ្លាស់ប្ដូរផ្នែករូបវន្តក៏បានកើតឡើងបន្តបន្ទាប់។ បរិវេណមណ្ឌលសុខភាព ត្រូវបាន ចាក់សាបរោងចំណតម៉ូតូត្រូវបានសាងសង់ របងត្រូវបានលាបពណ៌ថ្មី ហើយខ្លោងទ្វារចូល និងសួនច្បារថ្មី បានផ្ដល់បរិយាកាសស្វាគមន៍ដល់អ្នកដែលមកទទួលសេវា។ តម្លាភាពកាន់តែប្រសើរឡើង ចំណែកព័ត៌មានលម្អិត ស្ដីពីចំណូល និងចំណាយ ត្រូវបានចែករំលែកជាសាធារណៈ ហើយសមាជិកសហគមន៍ទទួលបានទំនុកចិត្តក្នុងការបញ្ចេញមតិរបស់ពួកគេ។ មណ្ឌលសុខភាពនេះក៏បានពង្រឹងសមត្ថភាពរបស់ខ្លួនផងដែរ តាមរយៈការ ផ្គត់ផ្គង់ឱសថគ្រប់គ្រាន់ បន្ទប់សម្រាលស្អាត គ្រែថ្មី ធុងអុកស៊ីហ្សែន និងឧបករណ៍ បរិក្ខារចាំបាច់ នានា។

ផលជះនេះមានទំហំធំធេង។ ចំនួនអ្នកជំងឺដែលមកទទួលសេវាប្រចាំខែ បានកើនឡើងបីដង ពោលគឺកើនពី ២៥០-៣០០ នាក់ដល់ជិត ៩០០ នាក់។ ចំនួនស្ត្រីមកសម្រាលកូន បានកើនដល់ ១៨-២០ នាក់ក្នុងមួយខែ ហើយបច្ចុប្បន្ន អ្នកជំងឺមិនត្រឹមតែមកពីឃុំស្វាយតាយានប៉ុណ្ណោះទេ ថែមទាំងមកពីឃុំជិតខាងទៀតផង។ ប្រជាពលរដ្ឋនិយាយអំពីភាពសប្បុរស និងភាពមានវិជ្ជាជីវៈសះ៖ "នៅទីនេះ អ្នកផ្ដល់សេវាថែទាំសុខភាព ផ្ដល់សេវាប្រកបដោយគុណភាពខ្ពស់។ បុគ្គលិកពេទ្យមានភាពរួសរាយរាក់ទាក់ ងាយស្រួលទំនាក់ទំនង និងផ្ដល់ការពិគ្រោះយោបល់និងដំបូន្មានបានល្អ។ ពួកគេមិនរើសអើងអ្នកជំងឺឡើយ ទោះជាអ្នកមាន ឬអ្នកក្រក្ដី។ អ្នកមកដល់មុនទទួលបានសេវាមុន រីឯអ្នកមកដល់ក្រោយទទួលបានសេវាតាមលំដាប់លំដោយ។ លើសពីនេះ មានតារាងតម្លៃសេវាច្បាស់លាស់ផ្អែកលើប្រភេទនៃជំងឺ"។ នេះជាការលើកឡើងរបស់អ្នកស្រី ស វណ្ណា អាយុ ៥៤ ឆ្នាំ មកពីភូមិព្រៃធ្លក។

"អ្នកផ្ដល់សេវាថែទាំសុខភាពនៅទីនេះ ផ្ដល់សេវាបានលឿនរហ័ស សូម្បីតែថ្ងៃដែលខ្ញុំមកដល់យឺត ដោយសារការលំបាកឆ្លងផ្លូវក៏ដោយ។ ខ្ញុំមកទីនេះញឹកញាប់ណាស់ ប៉ុន្តែខ្ញុំមិនដែលឃើញបុគ្គលិក ណាម្នាក់បង្ហាញ ទឹកមុខមិនពេញចិត្ត ឬនិយាយស្ដីអាក្រក់ដាក់អ្នកជំងឺឡើយ។ ពួកគេតែងតែមានចិត្តល្អ និងកាយវិកាទន់ភ្លន់ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកជំងឺ"។ នេះជាការលើកឡើងរបស់អ្នកស្រី ងួន យ៉ា អាយុ ៧៤ ឆ្នាំ មកពីភូមិព្រៃស្មៀង។

លោក បូរ៉ាន់ បានគូសបញ្ជាក់ថា សមិទ្ធផលទាំងនេះកើតចេញពី "សាមគ្គីភាព និងការងារជាក្រុម ដ៏រឹងមាំរបស់បុគ្គលិក កិច្ចសហការប្រកបដោយប្រសិទ្ធភាពជាមួយអាជ្ញាធរមូលដ្ឋាន និងសប្បុរសជន និងការគាំទ្រ ជាបន្តបន្ទាប់ពីមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ។" លោកបានបន្ថែមទៀតថា បច្ចុប្បន្នមណ្ឌលសុខភាពនេះ "ផ្ដល់ការអប់រំដល់សហគមន៍តាមរយៈរូបភាព ផ្គត់ផ្គង់ឱសថ និងបរិក្ខារពេទ្យគ្រប់គ្រាន់ ថែរក្សាបន្ទប់សម្រាលកូន ឱ្យមានអនាម័យល្អ និងបានកៀរគរការគាំទ្រពីសប្បុរសជន ដើម្បីបន្តអភិវឌ្ឍ និងកែលម្អមណ្ឌល សុខភាពនេះបន្ថែមទៀត"។

តទៅមុខ មណ្ឌលសុខភាពស្វាយតាយាន មានផែនការរក្សាការរៀបចំកិច្ចប្រជុំគណៈគ្រប់គ្រងជាប្រចាំ ធានាការផ្គត់ផ្គង់ឱសថ កែលម្អអនាម័យ និងពង្រឹងសេវាពិគ្រោះជំងឺក្រៅ ដែលចំណុចទាំងអស់នេះសុទ្ធតែផ្អែកតាម ផ.ស.រ.គ។ ធ្លាប់តែជាមណ្ឌលសុខភាពដែលជួបការលំបាក ពេលនេះបានក្លាយជានិមិត្តរូបនៃវឌ្ឍនភាព និងគណនេយ្យភាព ជាទីដែលទំនុកចិត្តត្រូវបានកសាងឡើងវិញ ហើយសេវាសុខភាពពិតជាបម្រើប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។

ធ្លាប់តែជាមណ្ឌលសុខភាពដែលជួបការលំបាក ពេលនេះបានក្លាយជានិមិត្តរូបនៃវឌ្ឍនភាព និងគណនេយ្យភាព ជាទីដែលទំនុកចិត្តត្រូវបានកសាងឡើងវិញ ហើយសេវាសុខភាពពិតជាបម្រើប្រជាពលរដ្ឋ យ៉ាងពិតប្រាកដ។ មណ្ឌលសុខភាពស្វាយតាយាន ស្ថិតក្នុងចំណោមមណ្ឌលសុខភាពទាំងប្រាំមួយ ដែលមាន ទីតាំងនៅឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង និងស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរពេទ្យបង្អែក ជីភូ ក្នុងក្រុងបាវិត។ រួមគ្នា មណ្ឌលទាំងនេះកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់សេវាថែទាំ សុខភាពចាំបាច់ នៅទូទាំង ១១ ឃុំ ដើម្បីធានាថា ប្រជាពលរដ្ឋរាប់ពាន់នាក់ទទួលបានសេវាថែទាំប្រកបដោយគុណភាព។














# ការពង្រឹងប្រព័ន្ធក្នុងមូលដ្ឋាន

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥

### កិច្ចការពារកុមារ និងការចូលរួម

ក្នុងនាមជាគ្រូបង្គោលថ្នាក់ជាតិ ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) អង្គការទស្សនៈពិភពលោកបានពង្រឹងសមត្ថភាព របស់ជនបង្គោលចំនួន ១.៩៨០ នាក់នៅទូទាំង ២២ ខេត្ត ក្រុង ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារថ្មីនៃកិច្ចការពារកុមារ (CP-SOPs)។ CP-SOPs ផ្តល់ការណែនាំអំពីការកំណត់អត្តសញ្ញាណ ការរាយការណ៍ ការឆ្លើយតប (រួមទាំងការគ្រប់គ្រងករណី) និងការបញ្ជូនករណីនៅពេលដែលកុមារប្រឈមនឹងហានិភ័យ ឬជួបប្រទះគ្រោះថ្នាក់ធ្ងន់ធ្ងរ។

### សុខភាព

អង្គការទស្សនៈពិភពលោកបានពង្រឹងសមត្ថភាពរបស់សមាជិកក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) ស្តីពីការ ថែទាំ និងអភិវឌ្ឍន៍កុមារតូច (ECCD) ការកំណត់រកបញ្ហាកង្វះអាហារូបត្ថម្ភ និងដំណើរការនៃការបញ្ជូន ទៅទទួលសេវា និងបានបង្កើនសមត្ថភាពរបស់បុគ្គលិកសុខាភិបាលក្នុងការកំណត់រកករណីពិការភាព ព្យាបាលជំងឺ រាករូសបានត្រឹមត្រូវ គ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភ បញ្ជ្រាបយេនឌ័រ និងធ្វើស្លាប័ន្ទបនីយកម្ម វិធីសាស្ត្រដែល យកចិត្តទុកដាក់ចំពោះទារក (ជាពិសេសផ្តោតលើការលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ)។

### ការអប់រំ

ដើម្បីកែលម្អគុណភាពនៃការបង្រៀន អង្គការទស្សនៈពិភពលោកបានគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេលើការ អនុវត្តគំនិតផ្តួចផ្តើមការសិក្សាកម្រិតថ្នាក់ដំបូង (កុមាររៀន កុមារចេះ)។

អង្គការទស្សនៈពិភពលោក បានសហកាជាមួយនាយកដ្ឋាននីតិកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រដល់ការផ្ទេរមុខងារពីមន្ទីរ និងការិយាល័យអប់រំខេត្ត-ស្រុក ទៅថ្នាក់ស្រុក/ក្រុង/ខណ្ឌ ក្រោមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលបំណងលើកកម្ពស់លទ្ធផលសិក្សារបស់កុមារ។

### ទឹកស្អាត និងអនាម័យ (WASH)

អង្គការទស្សនៈពិភពលោក និងដៃគូ បានពង្រឹងប្រព័ន្ធទឹកស្អាត និងអនាម័យថ្នាក់ក្រោមជាតិ ដោយគាំទ្រដល់រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន។ ពួកគេបានធ្វើការជាមួយស្ថាប័ននានា ដូចជា ក្រុមការងារសម្របសម្រួលទឹកស្អាត និងអនាម័យថ្នាក់ស្រុក ដើម្បីពិនិត្យ និងកែសម្រួលផែនការទឹកស្អាត និងអនាម័យថ្នាក់ស្រុក ដោយរួមបញ្ចូលនូវចីរភាពភាពធន់នឹងអាកាសធាតុ ព្រមទាំងយេនឌ័រ និងបរិយាបន្នសង្គម។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមានគោលបំណងកសាងសមត្ថភាពបច្ចេកទេស និងសមត្ថភាព ហិរញ្ញវត្ថុរបស់មន្ត្រីឃុំក្នុងការគ្រប់គ្រងសេវាទឹកស្អាត និងអនាម័យដោយផ្លាស់ប្តូរតួនាទីពួកគេពីអ្នកទទួលជំនួយ ទៅជាអ្នកសម្របសម្រួលសេវាយ៉ាងសកម្ម។

# ការពង្រឹងប្រព័ន្ធក្នុងមូលដ្ឋាន

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥








### របរចិញ្ចឹមជីវិត

អង្គការទស្សនៈពិភពលោក បានសម្របសម្រួលជាមួយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលើកឡើងពីបញ្ហារបស់កសិករ និងសហគមន៍កសិកម្មទៅកាន់ អ្នកបង្កើតគោលនយោបាយ តាមរយៈព្រឹត្តិការណ៍សាធារណៈមួយ។
រួមជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) អង្គការទស្សនៈពិភពលោក បានពង្រឹងក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីឱ្យពួកគេយល់កាន់ តែច្បាស់ពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន។

### គ្រប់គ្រងគ្រោះមហន្តរាយ

អង្គការទស្សនៈពិភពលោកបានកៀរគរគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និងវេទិកាឆ្លើយតបមនុស្សធម៌ (HRF) ដើម្បីដឹកនាំការវាយតម្លៃតម្រូវការបន្ទាន់នៃការស្តារឡើងវិញទាន់ពេលវេលា ពហុវិស័យរួមគ្នា ដែលជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រ ឆ្លើយតបរួមគ្នាទៅនឹងតម្រូវការរបស់ ជនភៀសសឹកក្នុងស្រុកនៅកម្ពុជា។

អង្គការទស្សនៈពិភពលោកបានធ្វើការវាយតម្លៃសុវត្ថិភាពផ្លូវចិត្តដើម្បីស្វែងយល់ពីការប៉ះទង្គិចផ្លូវចិត្តដែលគ្រួសាររងផលប៉ះពាល់ដោយជម្លោះបានជួបប្រទះ និងដើម្បីណែនាំអំពីកិច្ចខិតខំប្រឹងប្រែងឆ្លើយតប។ អនុសាសន៍សំខាន់ៗ រួមមានការផ្តល់លទ្ធភាពទទួលបានអ្នកប្រឹក្សាយោបល់ ដែលមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ភ្លាមៗ ការកសាងការយល់ដឹងអំពីសេវាគាំទ្រ ការបង្កើតប្រព័ន្ធបែងចែក និងបញ្ជូនអ្នកជំងឺ នៅក្នុងមជ្ឈមណ្ឌលសុវត្ថិភាព ការសម្របសម្រួលក្រុមមិត្តជួយមិត្ត សម្រាប់មនុស្សពេញវ័យ និងការសម្របសម្រួល វគ្គព្យាបាលការប៉ះទង្គិចផ្លូវចិត្តសម្រាប់កុមារ។

អង្គការទស្សនៈពិភពលោកបានគាំទ្រដល់ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ សម្រាប់ទីតាំងភៀសសឹក និងបានបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលជាដៃគូនៅខេត្តព្រះវិហារ ដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពនៃការចែកជំនួយមនុស្សធម៌។



# ដើម្បីជីវិត

ការប្តេជ្ញាចិត្តរបស់យើង
ក្នុងការបង្កើតឱ្យមានការផ្លាស់ប្រែដ៏យូរអង្វែង

# ការអភិវឌ្ឍប្រកបដោយការផ្លាស់ប្រែ

ភាពក្រីក្រគឺជាការបញ្ចូលគ្នានៃទុក្ខកង្វល់ ភាពខ្វះខាត ភាពងាយរងគ្រោះ និងទំនាក់ទំនងបែកបាក់ ដែលគំរាមកំហែងដល់ភាពរស់រានមានជីវិតរបស់មនុស្ស និងរារាំងមិនឱ្យមនុស្សសម្រេចបានសក្តានុពលដែលព្រះជាម្ចាស់ប្រទានឱ្យ។ ការអភិវឌ្ឍប្រកបដោយការផ្លាស់ប្រែ គឺជារបៀបដែលអង្គការទស្សនៈពិភពលោកឆ្លើយតបទៅនឹងភាពក្រីក្រ និងភាពងាយរងគ្រោះ និងខិតខំសម្រេចបានទស្សនវិស័យនៃ "ជីវិតពេញបរិបូរណ៍" សម្រាប់កុមារគ្រប់រូបនៅក្នុងគ្រប់បរិបទ។ ការអភិវឌ្ឍប្រកបដោយ ការផ្លាស់ប្រែ គឺជាដំណើរការ ៦ ជំហាននៃការរៀនសូត្រ និងការផ្លាស់ប្រែរួមគ្នា៖

**១. ស្តាប់៖** យើងស្តាប់ព្រះជាម្ចាស់ និងមនុស្សដែលយើងបម្រើ

**២. រួមបញ្ចូល៖** យើងប្តេជ្ញាគ្របដណ្តប់ដល់ និងរួមបញ្ចូលកុមារដែលងាយរងគ្រោះបំផុត

**៣. បង្កើនភាពអង់អាច៖** ដល់សហគមន៍ គ្រួសារ និងកុមារ ក្នុងការរៀបចំ និងគ្រប់គ្រងដំណើរការផ្លាស់ប្រែរបស់ពួកគេផ្ទាល់

**៤. ផ្សារភ្ជាប់៖** ភាពម្ចាស់ការក្នុងមូលដ្ឋាន និងសមត្ថភាពក្នុងការរក្សាភាពប្រសើរឡើងនៃការអភិវឌ្ឍកុមារ

**៥. ដេញដោល៖** ច្បាប់ ប្រព័ន្ធ និងការអនុវត្តដែលបណ្តោយឱ្យមានភាពក្រីក្រ និងភាពងាយរងគ្រោះ របស់កុមារ

**៦. សម្របសម្រួល៖** ទៅនឹងបរិបទដែលយើងធ្វើការ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញ

# គោលនយោបាយការពារកុមារ និងមនុស្សពេញវ័យ

នៅគ្រប់ភារកិច្ចទាំងអស់នៃការងាររបស់យើង យើងធានាការអនុវត្តវិធីសាស្រ្ត "មិនបង្កគ្រោះថ្នាក់" ប្រកបដោយសង្គតិភាពជាមួយភាគីពាក់ព័ន្ធនឹងកម្មវិធីរបស់យើង។ សសរស្តម្ភទាំង ៣ របស់យើង នៃការអនុវត្តកម្មវិធីប្រកបដោយសុវត្ថិភាពគឺ ការការពារ ការរាយការណ៍ និងការឆ្លើយតប គឺជាលក្ខខណ្ឌចាំបាច់ បំផុតនៃអ្វីគ្រប់យ៉ាងដែលយើងប្រតិបត្តិការងារជារៀងរាល់ថ្ងៃ។

ការិយាល័យរបស់យើងនៅកម្ពុជាអនុលោមតាមបទដ្ឋាន និងប្រព័ន្ធគោលនយោបាយការពារកុមារ និង មនុស្សពេញវ័យរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលបានរួមបញ្ចូលក្នុងមុខងារទាំងអស់ របស់ស្ថាប័នទាំងមូល រាប់ចាប់តាំងពីការិយាល័យថ្នាក់ជាតិរបស់យើងនៅរាជធានីភ្នំពេញ រហូតដល់សហគមន៍ ដាច់ស្រយាលបំផុតដែលយើងបម្រើ។

ការវាយតម្លៃចុងក្រោយនេះបង្ហាញពីកម្រិតខ្ពស់នៃប្រសិទ្ធភាពការអនុវត្តកម្រិតសកលរបស់យើង ហើយនេះ ជាអត្តសញ្ញាណនៃការប្តេជ្ញាចិត្តខ្ពស់នៃអនុលោមភាពទៅនឹងបទដ្ឋានសកលដែលតម្កល់ការប្តេជ្ញាចិត្តលើគោលនយោបាយមិនអត់ឱន (Zero tolerance) ដើម្បីកាត់បន្ថយភាពចន្លោះ ប្រហោងនៃការអនុវត្តគោលនយោបាយ ការពារកុមារ និងមនុស្សពេញវ័យនៅអាស៊ីប៉ូពា៌។



# យើងជាដៃគូ

## នៅឆ្នាំ ២០២៥ យើងមាន ៣ លានហេតុផល ដែលត្រូវថ្លែងអំណរគុណ។

សមិទ្ធផលនៃឆ្នាំនេះនឹងមិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការគាំទ្រឥតងាករេពីដៃគូទាំងអស់របស់យើងនៅកម្ពុជា និងនៅបរទេស។ ដោយសារពួកគេទើបយើងអាចពង្រីកផលជះរបស់យើង និងបម្រើកុមារចំនួន ៣ លាននាក់ ដើម្បីបន្តកសាងអនាគតប្រកបដោយវិបុលភាពសម្រាប់ប្រទេសកម្ពុជា។

ទំព័រខាងក្រោមជាការទទួលស្គាល់តួនាទីសំខាន់ៗរបស់ក្រសួងពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារអង្គការសហប្រជាជាតិ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (INGOs) និងអង្គការសង្គមស៊ីវិល (CSOs) ក្នុងការផ្តល់ឱកាសផ្លាស់ប្រែជីវិតដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត។

## សូមថ្លែងអំណរគុណចំពោះការចូលរួមយូរអង្វែងជាមួយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)
- ក្រសួងសុខាភិបាល
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងព័ត៌មាន

# យើងជាដៃគូ

- សូមថ្លែងអំណរគុណចំពោះភាពជាដៃគូដែលប្រកបដោយផលប៉ះពាល់ជាមួយ
**សហគមន៍អភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា**

## សូមថ្លែងអំណរគុណចំពោះភាពជាដៃគូដែលប្រកបដោយផលប៉ះពាល់ជាមួយ
## សហគមន៍អភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា

## សូមថ្លែងអំណរគុណចំពោះភាពជាដៃគូដែលប្រកបដោយផលប៉ះពាល់ជាមួយ
## សហគមន៍អភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា

## សូមថ្លែងអំណរគុណចំពោះភាពជាដៃគូដែលប្រកបដោយផលប៉ះពាល់ជាមួយសហគមន៍អភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា

សមិទ្ធផលនៃឆ្នាំនេះនឹងមិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការគាំទ្រតងាករពីដៃគូទាំងអស់របស់ យើងនៅកម្ពុជា និងនៅបរទេស។ ដោយសារពួកគេទើបយើងអាចពង្រីកផលជះរបស់យើង និងបម្រើកុមារចំនួន ៣ លាននាក់ ដើម្បីបន្តកសាងអនាគតប្រកបដោយវិបុលភាពសម្រាប់ប្រទេសកម្ពុជា។

# ការបែងចែកថវិកា

**ឆ្នាំសារពើពន្ធ ២០២៥ | ខែតុលា ២០២៤ – ខែកញ្ញា ២០២៥**

| ប្រភពមូលនិធិ៖ | % |
| --- | --- |
| មូលនិធិឯកជន<br>ការទំនុកបម្រុងកុមារ/អ្នកទំនុកបម្រុង | ៦៩% |
| ម្ចាស់ជំនួយធំៗ ក្រុមហ៊ុន ការបរិច្ចាគជាសម្ភារៈ | ១១% |
| ជំនួយឥតសំណង | ២០% |

| ការចំណាយ បែងចែកជាប្រភេទ៖ | % |
| --- | --- |
| គណនេយ្យភាពសង្គម និងការចូលរួមរបស់សហគមន៍ | ៣៥% |
| ការអប់រំ និងការអភិវឌ្ឍបំណិនជីវិត | ២២% |
| សុខភាព និងអាហារូបត្ថម្ភ (រួមទាំងការបង្ការជំងឺឆ្លង  របរចិញ្ចឹមជីវិត ភាពធន់ផ្នែកសេដ្ឋកិច្ច និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទឹកស្អាត និងអនាម័យ) | ២៣% |
| កិច្ចការពារកុមារ និងការវិនិយោគលើបំណិនជីវិតរបស់យុវជន | ២០% |


INTER
HONDA



World Vision

CAMBODIA

អង្គការទស្សនៈពិភពលោកគឺជាដៃគូអន្តរជាតិមួយនៃគ្រិស្តបរិស័ទ ដែលមានបេសកកម្មដើរតាម
ព្រះអម្ចាស់ ព្រះយេស៊ូគ្រិស្ត ជាព្រះសង្គ្រោះ ដោយធ្វើការជាមួយជនក្រីក្រ និងជនដែល
រងការគាបសង្កត់ដើម្បីបង្កើតអោយមានការផ្លាស់ប្រែដល់មនុស្សជាតិ ស្វែងរកភាពយុត្តិធម៌
និងធ្វើបន្ទាល់ពីដំណឹងល្អនៃនគរព្រះ។

**ទស្សនវិស័យរបស់យើងគឺចង់ឃើញកុមារគ្រប់រូប "មានជីវិតពេញបរិបូរណ៍"។**
**សេចក្តីអធិស្ឋានរបស់យើង សូមឱ្យទឹកចិត្តមនុស្សគ្រប់រូប "មានឆន្ទៈដើម្បីសម្រេចបំណងនេះ"។**

www.wvi.org/cambodia

Facebook • LinkedIn • Instagram • YouTube :